ក N°39/15-27/5/2015

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


| | | |
|---|---|---|
| ១៨-៥-២០១៥ | -ព្រះរាជក្រម នស/រកម/០៥១៥/០០៤ ស្តីពី ការត្រួតពិនិត្យផលិតផលថ្នាំជក់ | ៤៥៤៣ |


### ២~ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ០៩-៥-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៤០៤ ស្តីពី ការតម្លើងថ្នាក់ដោយផ្លោះឋានន្តរស័ក្តិ ដល់មន្ត្រីរាជការ ចំនួន ២០ រូប នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា សម្រាប់ឆ្នាំ ២០១៣ ចាប់ពី ខែមេសា ឆ្នាំ ២០១៥ | ៤៥៥៨ |
| ០៩-៥-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៤០៥ ស្តីពី ការតម្លើងថ្នាក់មួយថ្នាក់ក្នុងឋានន្តរស័ក្តិឧត្តមអភិបាល នៃក្របខ័ណ្ឌអភិបាល ដល់មន្ត្រីរាជការ ចំនួន ០៨ រូប នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា សម្រាប់ឆ្នាំ ២០១៣ ចាប់ពី ខែមេសា ឆ្នាំ ២០១៥ | ៤៥៦០ |
| ០៩-៥-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៤០៦ ស្តីពី ការតែងតាំង និងផ្តល់ឋានៈ ជាលេខាធិការ នៃការិយាល័យថ្នាក់ដឹកនាំតំណាងរាស្ត្រ នៃគណបក្សប្រជាជនកម្ពុជា ក្នុងនីតិកាលទី ៥ នៃរដ្ឋសភា ចំនួន ០២ រូប | ៤៥៦២ |
| ០៩-៥-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៤០៧ ស្តីពី ការតែងតាំង និងផ្តល់ឋានៈ ជាលេខាធិការ នៃការិយាល័យថ្នាក់ដឹកនាំតំណាងរាស្ត្រ នៃគណបក្សសង្គ្រោះជាតិ នីតិកាលទី ៥ នៃ រដ្ឋសភា ចំនួន ០២ រូប | ៤៥៦៣ |
| ០៩-៥-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៤០៨ ស្តីពី ការតែងតាំងឯកឧត្តម **ប៉ូ សុវណ្ណារ៉េត** ជានាយកខុទ្ទកាល័យអនុប្រធានទី ២ ព្រឹទ្ធសភា នីតិកាលទី ៣ មានឋានៈស្មើ អគ្គនាយក | ៤៥៦៤ |
| ១១-៥-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៤៣២ ស្តីពី ការតែងតាំងលោក **ឡុង ឌីណាល់** ជាឧកញ៉ា | ៤៥៦៥ |
| ១១-៥-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៤៣៣ ស្តីពី ការតែងតាំងលោក **ឈុន ចេតនា** ជាឧកញ៉ា | ៤៥៦៦ |
| ១១-៥-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៤៣៤ ស្តីពី ការតែងតាំងជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី ៣ មានឋានៈស្មើ រដ្ឋលេខាធិការ ចំនួន ០២ រូប | ៤៥៦៧ |

| | | |
|---|---|---|
| ១២-៥-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៤៣៥ ស្តីពី ការតែងតាំងលោក **ចាប ហុងលី** ជា ឧកញ៉ា | ៤៩៦៨ |
| ១២-៥-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៤៣៦ ស្តីពី ការតែងតាំងលោក **ម៉ែន ស៊ីនេត (ភាក់)** ជា ឧកញ៉ា | ៤៩៦៩ |
| ១២-៥-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៤៣៧ ស្តីពី ការតែងតាំងលោក **ជាម យុនណាត** ជា ឧកញ៉ា | ៤៩៧០ |
| ១៦-៥-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៤៤២ ស្តីពី ការផ្ទេរបញ្ចូល ជាករណីពិសេស លោកស្រី **ហឿង ឃឿង** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ | ៤៩៧១ |
| ១៦-៥-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៤៤៣ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជាករណីពិសេស ដល់មន្ត្រីរាជការ ចំនួន ០៤ រូប នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ | ៤៩៧២ |
| ១៦-៥-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៤៤៤ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ដល់វរសេនីយ៍ឯក **សេក រស់** នាយទាហាន ថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ | ៤៩៧៣ |
| ១៦-៥-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៥១៥/៤៤៥ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ដល់នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ៤០ រូប | ៤៩៧៤ |


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


| | | |
|---|---|---|
| ២០-៥-២០១៥ | -អនុក្រឹត្យលេខ ៦២ អនក្រ.បក ស្តីពី ការបង្កើតវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ | ៤៩៧៦ |
| ២១-៥-២០១៥ | -អនុក្រឹត្យលេខ ៦៣ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា | ៤៩៨០ |
| ២២-៥-២០១៥ | -អនុក្រឹត្យលេខ ៦៤ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា | ៤៩៨២ |
| ១៨-៥-២០១៥ | -អនុក្រឹត្យលេខ ៥១៧ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា | ៤៩៩០ |
| ១៩-៥-២០១៥ | -អនុក្រឹត្យលេខ ៥២៥ អនក្រ.តត ស្តីពី ការសំរួលភារកិច្ចមន្ត្រី នគរបាលជាតិកម្ពុជា | ៤៩៩២ |
| ១៩-៥-២០១៥ | -អនុក្រឹត្យលេខ ៥២៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ | ៤៩៩៣ |
| ១៩-៥-២០១៥ | -អនុក្រឹត្យលេខ ៥២៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ | ៤៩៩៤ |
| ១៩-៥-២០១៥ | -អនុក្រឹត្យលេខ ៥២៨ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា | ៤៩៩៥ |
| ១៩-៥-២០១៥ | -អនុក្រឹត្យលេខ ៥២៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ | ៤៩៩៧ |
| ១៩-៥-២០១៥ | -អនុក្រឹត្យលេខ ៥៣០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ | ៤៩៩៩ |

១៩-៥-២០១៥ -អនុក្រឹត្យលេខ ៥៣១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៦០១

២០-៥-២០១៥ -អនុក្រឹត្យលេខ ៥៣២ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ ៤៦០៣

២០-៥-២០១៥ -អនុក្រឹត្យលេខ ៥៣៣ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៤៦០៤

២០-៥-២០១៥ -អនុក្រឹត្យលេខ ៥៣៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤៦០៥

២០-៥-២០១៥ -អនុក្រឹត្យលេខ ៥៣៥ អនក្រ.តត ស្តីពី ការផ្ទេរ បញ្ចូលក្របខ័ណ្ឌ និងប្រគល់ឋានន្តរស័ក្តិ ៤៦០៧

២០-៥-២០១៥ -អនុក្រឹត្យលេខ ៥៣៦ អនក្រ.តត ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ៤៦០៨

២០-៥-២០១៥ -អនុក្រឹត្យលេខ ៥៣៧ អនក្រ.តត ស្តីពី ការធ្វើនិយ័តកម្មថ្នាក់មន្ត្រីរាជការ ៤៦១០

២០-៥-២០១៥ -អនុក្រឹត្យលេខ ៥៣៨ អនក្រ.តត ស្តីពី ការកំណត់ប្រភេទក្របខ័ណ្ឌមន្ត្រីរាជការ ៤៦១១

២០-៥-២០១៥ -អនុក្រឹត្យលេខ ៥៣៩ អនក្រ.តត ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ៤៦១៣


## ២-សេចក្តីសម្រេច


១៨-៥-២០១៥ -សេចក្តីសម្រេចលេខ ៣៥ សសរ ស្តីពី ការរៀបចំចងសម្ព័ន្ធមេត្រីភាពរវាងបញ្ជាការដ្ឋានរថក្រោះកងទ័ពជើងគោក ជាមួយអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៤៦១៥


## III-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


២៨-៤-២០១៥ -ប្រកាសអន្តរក្រសួងលេខ ៤៩២ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៥ របស់អាជ្ញាធរសវនកម្មជាតិ ៤៦១៦

២៩-៤-២០១៥ -ប្រកាសលេខ ៤៩៥ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៥ របស់អគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៤៦២១


## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម


៣០-៣-២០១៥ -ប្រកាសលេខ ១៣៧ ឧស.កឧ.ប្រក.០៣ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន គ្រីស្តាល់ម៉ាទីន (ខេមបូឌា) លីមីធីត បង្កើតរោងចក្រផលិត សម្លៀកបំពាក់ ៤៦២៥

៣០-៣-២០១៥ -ប្រកាសលេខ ១៣៨ ឧស.កឧ.ប្រក.០៣ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សេអ៊ីល (ខេមបូឌា) បង្កើតរោងចក្រផលិត សម្លៀកបំពាក់ ៤៦២៨

# ព្រះរាជក្រម

នស/រកម/០៥១៥/០០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

# ច្បាប់
# ស្តីពី
# ការត្រួតពិនិត្យ
# ផលិតផលថ្នាំជក់

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងការពារសុខភាពសាធារណៈ និងកាត់បន្ថយផលប៉ះពាល់ដល់សុខភាព សេដ្ឋកិច្ច សង្គម និងបរិស្ថាន ដែលបណ្តាលមកពីផលិតផលថ្នាំជក់ ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅដូចតទៅ ៖

- កំណត់វិធានការក្នុងការគ្រប់គ្រង និងត្រួតពិនិត្យផលិតផលថ្នាំជក់ ។
- លើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់សាធារណជន អំពីគ្រោះថ្នាក់នៃការប្រើប្រាស់ផលិតផលថ្នាំជក់
- សហការជាមួយបណ្តាក្រសួង ស្ថាប័នជាតិ អន្តរជាតិ និងអង្គការដៃគូនានា ដើម្បីជំរុញការអប់រំ និងកាត់បន្ថយការប្រើប្រាស់ផលិតផលថ្នាំជក់ ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពអនុវត្តលើគ្រប់សកម្មភាពពាក់ព័ន្ធនឹងផលិតផលថ្នាំជក់គ្រប់ប្រភេទ ដែលផលិតនៅក្នុងស្រុក ឬនាំចូលពីបរទេស ហើយចែកចាយ លក់ និងប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងច្បាប់នេះមាននិយមន័យដូចតទៅ ៖

- **ផលិតផលថ្នាំជក់** សំដៅដល់ផលិតផលគ្រប់ប្រភេទផ្សំឡើងពីសន្លឹកថ្នាំជក់ សរសៃថ្នាំជក់ ឬសារជាតុនៃថ្នាំជក់ដែលផលិតដោយឧស្សាហកម្មថ្នាំជក់ ឬដោយមធ្យោបាយផ្សេងៗទៀតដែលប្រើប្រាស់សម្រាប់ជក់ដោយផ្ទាល់ ឬដោយទម្រង់ផ្សេងៗទៀត រួមមាន ជញ្ជក់ ទំពា ចុក ឬហិត ។
- **ឧស្សាហករថ្នាំជក់** សំដៅដល់ផលិតករថ្នាំជក់ អ្នកលក់ដុំ និងអ្នកនាំចូលផលិតផលថ្នាំជក់ ។
- **ការឧបត្ថម្ភវិធីដោយឧស្សាហកម្មថ្នាំជក់** សំដៅដល់រាល់ទម្រង់នៃវិភាគទានចំពោះព្រឹត្តិការណ៍ សកម្មភាព ឬបុគ្គលណាមួយ ដោយមានគោលបំណងមានអានុភាពលើ ឬអាចមានអានុភាពលើការផ្សព្វផ្សាយផលិតផលថ្នាំជក់ ឬការប្រើប្រាស់ផលិតផលថ្នាំជក់ ដោយផ្ទាល់ ឬដោយប្រយោល ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ព្រះបរមរាជវាំង

- **កញ្ចប់ផលិតផលថ្នាំជក់** សំដៅដល់ប្រអប់ ក្រដាស គ្រឿងរុំពីក្រៅ ឬវត្ថុវេចខ្ចប់ផលិតផលថ្នាំជក់ ដោយមិនរាប់បញ្ចូលបារី ឬវត្ថុសម្រាប់ផ្ទុកផលិតផលថ្នាំជក់របស់កសិករ ។
- **សារព្រមានសុខភាព** សំដៅដល់សារជាភាសាខ្មែរ និងជារូបភាពដែលបោះពុម្ពលើកញ្ចប់ផលិតផលថ្នាំជក់ បង្ហាញពីគ្រោះថ្នាក់នៃការប្រើប្រាស់ថ្នាំជក់ និងព័ត៌មាន ពាក់ព័ន្ធផ្សេងទៀត ។
- **គ្រឹះស្ថានសិក្សា** សំដៅដល់មជ្ឈមណ្ឌលអប់រំ សិក្សា បណ្តុះបណ្តាល ដោយគិតចាប់ពីកម្រិតមត្តេយ្យសិក្សាដល់ឧត្តមសិក្សា ទោះជាប្រភេទសាលារៀន ឬវិទ្យាស្ថាន ឬសាកលវិទ្យាល័យ ឬមជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈគ្រប់កម្រិត ។
- **គ្រឹះស្ថានសុខាភិបាល** សំដៅដល់ប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព មន្ទីរពេទ្យ គ្លីនិកសុខភាពទាំងរដ្ឋ ទាំងឯកជន ឱសថស្ថាន មន្ទីរពិសោធន៍សុខាភិបាលជាដើម ។
- **បរិយាកាសគ្មានផ្សែងថ្នាំជក់** សំដៅដល់ខ្យល់ដែលគ្មានផ្សែងថ្នាំជក់ ១០០% រួមទាំងខ្យល់ដែលមិនអាចមើលឃើញផ្សែងថ្នាំជក់ ធុំក្លិន ឬវាស់ស្ទង់បាន ។
- **គ្រឹះស្ថានសាសនា** សំដៅដល់ព្រះវិហារ ធម្មសភា សាលាបុណ្យ កុដិ បណ្ណាល័យ សាលា ពុទ្ធិកសិក្សា អាស្រម មណ្ឌលវិបស្សនា វិហារស៊ូរ៉ាវ ជាដើម ដែលទីកន្លែងទាំងនោះ ប្រើប្រាស់ក្នុងគោលបំណងគោរពបូជាសាសនាផ្សេងៗក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២
## សមត្ថកិច្ចត្រួតពិនិត្យថ្នាំជក់

### មាត្រា ៥.-

ក្រសួងសុខាភិបាលជាស្ថាប័នមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យរាល់សកម្មភាពពាក់ព័ន្ធនឹងផលិតផលថ្នាំជក់គ្រប់ប្រភេទដែលបញ្ញត្តក្នុងច្បាប់នេះ ។

### មាត្រា ៦.-

ក្រសួងសុខាភិបាលជាស្ថាប័នបង្គោលជាតិសម្រាប់ទំនាក់ទំនងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងបណ្តារដ្ឋភាគីនៃអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ របស់អង្គការសុខភាពពិភពលោក និងលេខាធិការដ្ឋាននៃអនុសញ្ញា ព្រមទាំងអង្គការជាតិ និងអង្គការអន្តរជាតិពាក់ព័ន្ធ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ៧.-**

រាជរដ្ឋាភិបាលត្រូវរៀបចំឲ្យមានគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ ដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ផលិតផលថ្នាំជក់ ។

គណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ ត្រូវដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣
## ការបង្ហាញព័ត៌មានសមាសធាតុក្នុងផលិតផលថ្នាំជក់ និងការដាក់បង្ហាញសារព្រមានសុខភាព

**មាត្រា ៨.-**

ផលិតករក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយ និងលក់ ក្នុងករណីមានតម្រូវការចាំបាច់ត្រូវផ្តល់ជូនក្រសួងសុខាភិបាលនូវព័ត៌មានលម្អិតអំពីសមាសធាតុដែលមានក្នុងផលិតផលថ្នាំជក់ និងផ្សែងថ្នាំជក់ ។

ព័ត៌មានលម្អិតអំពីសមាសធាតុដែលមានក្នុងផលិតផលថ្នាំជក់ និងផ្សែងថ្នាំជក់ ត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ៩.-**

ការប្រើប្រាស់ពាក្យដែលទាក់ទាញ និងធ្វើឲ្យយល់ច្រឡំ ជាអាទិ៍ ក្លិនឈ្ងុយឆ្ងាញ់ រសជាតិស្រាល រសជាតិស្រាលស្រទន់ រសជាតិវីតាមីន ការហ្វេអ៊ីនក្នុងផលិតផលថ្នាំជក់ ត្រូវហាមឃាត់ ។

**មាត្រា ១០.-**

ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទ សម្រាប់ធ្វើការចែកចាយលក់ និងប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់ អំពីគ្រោះថ្នាក់នៃការប្រើប្រាស់ផលិតផលថ្នាំជក់ ។

សារព្រមានសុខភាពជារូបភាព ត្រូវមានទំហំ ៥០ (ហាសិប) ភាគរយយ៉ាងតិច ។ ការបោះពុម្ពសារព្រមានសុខភាពជាអក្សរ និងរូបភាព ត្រូវកំណត់ដោយអនុក្រឹត្យ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ៤
## វិធានការចំពោះការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធីដោយឧស្សាហករថ្នាំជក់

**មាត្រា ១១.-**

ការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់តាមប្រព័ន្ធផ្សព្វផ្សាយជារូបភាព ឬជាអក្សរ ឬជាសំឡេង តាមរយៈវិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្តី ស៊ីឌី វីស៊ីឌី ឌីវីឌី សេវាប្រៃសណីយ៍ សេវាទូរគមនាគមន៍ និងតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀត ត្រូវហាមឃាត់ ។

ការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ជាផ្ទាំងរូបភាព ផ្ទាំងប៉ាណូ ផ្ទាំងបដា ផ្ទាំងគំនូរ ឬបណ្ណផ្សព្វផ្សាយ ផលិតផលថ្នាំជក់ផ្សេងៗទៀតជាសាធារណៈ និងការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ជារូបភាពចល័ត នៅលើជញ្ជាំងរថយន្ត ឬលើយានជំនិះ និងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ ត្រូវហាមឃាត់ ។

ការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ដល់សាធារណជននៅតាមទីកន្លែងសាធារណៈណាមួយ ដូចជាក្នុងកម្មវិធីប្រគំតន្ត្រី ឬកម្មវិធីកីឡា ឬកម្មវិធីផ្សេងៗទៀត និងការលើកកម្ពស់ការផ្សព្វផ្សាយផលិតផល ថ្នាំជក់ដល់អតិថិជនដោយផ្ទាល់ ឬដោយប្រយោល ដោយភ្នាក់ងារក្រុមហ៊ុនផលិតថ្នាំជក់ ត្រូវហាមឃាត់ ។

**មាត្រា ១២.-**

ចំពោះការដាក់តាំងបង្ហាញកញ្ចប់ផលិតផលថ្នាំជក់ធម្មតា អាចធ្វើទៅបាននៅតែនៅនឹងកន្លែងលក់ ឬតូបលក់ ឬក្នុងហាងលក់បារីផ្ទាល់តែប៉ុណ្ណោះ ។

ទំហំ និងចំនួននៃកញ្ចប់ផលិតផលថ្នាំជក់ដែលដាក់តាំងបង្ហាញ ឬបិទនៅនឹងកន្លែងលក់ ឬតូបលក់ ឬក្នុងហាងលក់បារី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ១៣.-**

ការឧបត្ថម្ភកម្មវិធីក្នុងការប្រគំតន្ត្រី ឬកម្មវិធីកីឡា ឬកម្មវិធីជាសាធារណៈផ្សេងៗទៀត ជាផលិតផលថ្នាំជក់ ឬជាសម្ភារៈដែលបង្ហាញពីឈ្មោះផលិតផលថ្នាំជក់ត្រូវហាមឃាត់ ។

## ជំពូកទី៥
## ការចែកចាយ ការលក់ និងទីកន្លែងលក់ផលិតផលថ្នាំជក់

**មាត្រា ១៤.-**

ការគ្រប់គ្រង និងត្រួតពិនិត្យលើការលក់រាយ ការចែកចាយ និងការលក់ដុំផលិតផលថ្នាំជក់គ្រប់ប្រភេទ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៥.-**

ការលក់ និងការចែកចាយផលិតផលថ្នាំជក់គ្រប់ប្រភេទដល់ជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ និងស្ត្រីដែលមានគភ៌ ត្រូវហាមឃាត់ កាលបើគភ៌នោះ ត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើអ្នកលក់បានដឹង ។

ការលក់រាយមួយកញ្ចប់ក្រោម ២០ ដើម ត្រូវហាមឃាត់ ។

**មាត្រា ១៦.-**

រាល់ការនាំយកមកជាមួយខ្លួននូវបារី ឬផលិតផលថ្នាំជក់ដើម្បីប្រើប្រាស់ផ្ទាល់ខ្លួន ចូលមកក្នុង ព្រះរាជាណាចក្រកម្ពុជា លើសពី ២០០ (ពីររយ) ដើម ឬស៊ីហ្គាលើស ៥០ (ហាសិប) ដើម ឬថ្នាំជក់ ទម្ងន់លើស ២៥០ (ពីររយហាសិប) ក្រាម ត្រូវហាមឃាត់ ។

ជនដែលមានអាយុតិចជាង ១៨ (ដប់ប្រាំបី) ឆ្នាំ មិនអនុញ្ញាតឲ្យនាំយកមកជាមួយខ្លួននូវ បារី ឬផលិតផលថ្នាំជក់ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

**មាត្រា ១៧.-**

ការលក់ និងចែកចាយផលិតផលថ្នាំជក់គ្រប់ប្រភេទ នៅក្នុងបរិវេណនៃគ្រឹះស្ថានសិក្សា គ្រឹះស្ថាន សុខាភិបាល សួនកុមារ គ្រឹះស្ថានសាសនា សារមន្ទីរ រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ កន្លែងហាត់ប្រាណ ស្ថានីយប្រេងឥន្ធនៈ និងកន្លែងងាយឆាបឆេះ ត្រូវហាមឃាត់ ។

ការលក់ផលិតផលថ្នាំជក់គ្រប់ប្រភេទ តាមមធ្យោបាយមិនផ្ទាល់ តាមរយៈម៉ាស៊ីនលក់ដោយ ស្វ័យប្រវត្តិ ការបញ្ជាទិញតាមប្រៃសណីយ៍ និងការបញ្ជាទិញតាមសេវាទូរគមនាគមន៍ផ្សេងៗ ត្រូវ ហាមឃាត់ ។

## ជំពូកទី ៦
## វិធានការការពារបរិយាកាស
## គ្មានផ្សែងផលិតផលថ្នាំជក់

**មាត្រា ១៨.-**

រាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ និងចាត់វិធានការការពារប្រជាពលរដ្ឋ ពីការប្រឈមនឹង ការស្រូបផ្សែងផលិតផលថ្នាំជក់ ដើម្បីជានាសិទ្ធិអ្នកមិនប្រើប្រាស់ផលិតផលថ្នាំជក់ ឲ្យទទួលបាន នូវបរិយាកាសដែលគ្មានផ្សែងផលិតផលថ្នាំជក់ ដើម្បីបង្ការនូវជំងឺផ្សេងៗដែលបណ្តាលមកពីការស្រូប ផ្សែងផលិតផលថ្នាំជក់ និងផលប៉ះពាល់ដល់សុខភាពដែលបង្កឡើងដោយផ្សែងផលិតផលថ្នាំជក់ ។

**មាត្រា ១៩.-**

វិធានការហាមការជក់ និងការបង្ហុយផ្សែងផលិតផលថ្នាំជក់ នៅកន្លែងធ្វើការ និងកន្លែង សាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

## ជំពូកទី ៧
## ការវាយតម្លៃអំពីហានិភ័យ ការតាមដាន ការត្រួតពិនិត្យ និងការសិក្សាស្រាវជ្រាវ

**មាត្រា ២០.-**

ក្រសួងសុខាភិបាលត្រូវសហការជាមួយគ្រប់ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាឲ្យមានការវាយតម្លៃសមស្របអំពីហានិភ័យនៃសកម្មភាពទាក់ទងនឹងផលិតផលថ្នាំជក់ សម្រាប់ធ្វើការតាមដាន ត្រួតពិនិត្យ និងសិក្សាស្រាវជ្រាវអំពីផលប៉ះពាល់លើសុខភាព សេដ្ឋកិច្ច បរិស្ថាន និងសង្គម ។

**មាត្រា ២១.-**

ក្រសួងសុខាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការសិក្សាស្រាវជ្រាវអំពីផលប៉ះពាល់ដល់សុខភាព សេដ្ឋកិច្ច បរិស្ថាន និងសង្គម ដោយផ្តោតលើការងារដូចខាងក្រោម ៖

- ការប្រើប្រាស់ផលិតផលថ្នាំជក់
- បរិមាណផលិតផលថ្នាំជក់ដែលនាំចេញ នាំចូល តម្លៃ និងការប្រើប្រាស់ថ្នាំជក់ វត្ថុធាតុដើម គ្រឿងម៉ាស៊ីន ប្រាក់ចំណូល ការដាំដំណាំថ្នាំជក់ និងព័ត៌មានផ្សេងៗទៀត
- ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយត្រួតពិនិត្យថ្នាំជក់ ។

**មាត្រា ២២.-**

ក្រសួងសុខាភិបាល និងស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំឲ្យមានក្រុមជំនាញវិទ្យាសាស្ត្រ និងមន្ទីរពិសោធន៍ ដើម្បីធ្វើតេស្តផលិតផលថ្នាំជក់ ជាពិសេស ស្តង់ដានៃសមាសធាតុ និងផលប៉ះពាល់ដែលកើតចេញពីការប្រើប្រាស់ផលិតផលថ្នាំជក់ ក្នុងករណីចាំបាច់ ត្រូវសហការជាមួយក្រុមជំនាញវិទ្យា-សាស្ត្រ និងមន្ទីរពិសោធន៍ក្នុងតំបន់ និងអន្តរជាតិ ។

## ជំពូកទី ៨
## ការផ្តល់ព័ត៌មាន ការលើកកម្ពស់ ការយល់ដឹង និងការចូលរួមរបស់សាធារណជន

**មាត្រា ២៣.-**

ក្រសួងសុខាភិបាល គណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ និងស្ថាប័នពាក់ព័ន្ធត្រូវលើកកម្ពស់ការយល់ដឹង ធ្វើការអប់រំ និងផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់សាធារណជន អំពីផលប៉ះពាល់លើសុខភាព សេដ្ឋកិច្ច និងបរិស្ថានដែលបណ្តាលមកពីការប្រើប្រាស់ផលិតផលថ្នាំជក់ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ក្រសួងសុខាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ ត្រូវសហការជាមួយ អាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរមូលដ្ឋាន សង្គមស៊ីវិល និងផ្នែកឯកជនដែលគ្មានទំនាក់ទំនងជាមួយ ឧស្សាហករថ្នាំជក់ដើម្បីជំរុញកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីផលវិបាកនៃកាប្រើប្រាស់ផលិតផល ថ្នាំជក់ ។

**មាត្រា ២៤.-**

ក្រសួងសុខាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ ត្រូវសហការជាមួយ ស្ថាប័នពាក់ព័ន្ធ ដើម្បីលើកទឹកចិត្តដល់ការចូលរួមរបស់សាធារណជន ក្នុងកម្មវិធីលើកកម្ពស់ការយល់ ដឹងជាសាធារណៈនៅទូទាំងប្រទេស តាមរយៈការអប់រំ និងយុទ្ធនាការផ្សព្វផ្សាយទូលំទូលាយ និង ជួយអ្នកប្រើប្រាស់ផលិតផលថ្នាំជក់ឲ្យឈប់ប្រើប្រាស់ផលិតផលថ្នាំជក់ ។

**មាត្រា ២៥.-**

អ្នកផ្តល់សេវាសុខាភិបាលគ្រប់ប្រភេទ ទាំងសាធារណៈ ទាំងឯកជន ត្រូវចូលរួម និងផ្តល់ការ អប់រំ ផ្សព្វផ្សាយអំពីផលវិបាកនៃការប្រើប្រាស់ផលិតផលថ្នាំជក់ ដល់សាធារណជន និងអតិថិជនរបស់ ខ្លួន ។

**មាត្រា ២៦.-**

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវបញ្ចូលកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីផលវិបាកនៃការ ប្រើប្រាស់ផលិតផលថ្នាំជក់ ទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ ទាំងសាធារណៈ និងឯកជន ។

**មាត្រា ២៧.-**

រាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ចំពោះកសិករ ដែលស្ម័គ្រចិត្តប្តូរការដាំដំណាំថ្នាំជក់ ទៅ ដំណាំផ្សេងវិញ ។

## ជំពូកទី ៩
## គោលនយោបាយពន្ធលើផលិតផលថ្នាំជក់

**មាត្រា ២៨.-**

រាជរដ្ឋាភិបាលត្រូវមានគោលនយោបាយដំឡើងពន្ធលើផលិតផលថ្នាំជក់គ្រប់ប្រភេទ ទៅតាម ស្ថានភាពសមស្រប ។

**មាត្រា ២៩.-**

រាជរដ្ឋាភិបាលត្រូវរៀបចំឲ្យមានមូលនិធិត្រួតពិនិត្យផលិតផលថ្នាំជក់ ដើម្បីកាត់បន្ថយការប្រើ- ប្រាស់ និងផលប៉ះពាល់នៃការប្រើប្រាស់ថ្នាំជក់ អប់រំសុខភាព លះបង់ទម្លាប់ប្រើប្រាស់ផលិតផលថ្នាំ-

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ជក់ ស្រាវជ្រាវ និងវាយតម្លៃកម្មវិធីត្រួតពិនិត្យផលិតផលថ្នាំជក់ និងសម្រាប់ជួយកសិករឱ្យលះបង់ការដាំដំណាំថ្នាំជក់ និងក្នុងគោលបំណងផ្សេងៗទៀត ដើម្បីបម្រើសុខភាពសាធារណៈ ។

មូលនិធិត្រួតពិនិត្យផលិតផលថ្នាំជក់នេះ ត្រូវបង្កើតដោយអនុក្រឹត្យ ។

## ជំពូកទី ១០
## អធិការកិច្ចផលិតផលថ្នាំជក់

### មាត្រា ៣០.-

ក្រសួងសុខាភិបាលត្រូវចាត់តាំងមន្ត្រីជំនាញរបស់ក្រសួង ជាមន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ ដើម្បីតាមដាន ត្រួតពិនិត្យ និងជំរុញការអនុវត្តច្បាប់នេះ ។

### មាត្រា ៣១.-

ក្នុងក្របខ័ណ្ឌនៃប្រតិបត្តិការទាក់ទងនឹងការធ្វើអធិការកិច្ចដែលមានចែងក្នុងច្បាប់នេះ មន្ត្រីអធិការកិច្ច ផលិផលថ្នាំជក់មានសិទ្ធិធ្វើការត្រួតពិនិត្យ និងចាត់វិធានការដូចខាងក្រោម ៖

- ធ្វើការត្រួតពិនិត្យជាប្រចាំទៅលើការប្រើប្រាស់ ការលក់ និងការផ្សព្វផ្សាយពាណិជ្ជកម្ម និងការបោះពុម្ពសារព្រមានសុខភាពលើផលិតផលថ្នាំជក់របស់ឧស្សាហករថ្នាំជក់
- ស្នើសុំត្រួតពិនិត្យ និងធ្វើតេស្តលើសមាសធាតុផលិតផលថ្នាំជក់ ដែលមាននៅក្នុងផលិតផលថ្នាំជក់ និងនៅក្នុងផ្សែងថ្នាំជក់
- ចាត់វិធានការហាមឃាត់ជាបណ្ដោះអាសន្នចំពោះការចែកចាយ ឬការចរាចរ លើទីផ្សារនូវប្រភេទផលិតផលថ្នាំជក់ទាំងឡាយណាដែលបានស្រាវជ្រាវឃើញនូវសមាសធាតុដែលបង្កហានិភ័យខ្ពស់ក្នុងផលិតផលថ្នាំជក់ ឬបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះសុខភាពមនុស្ស និងបរិស្ថាន
- ត្រួតពិនិត្យ និងពិន័យអន្តរការណ៍ចំពោះការមិនអនុវត្តបទដ្ឋានគតិយុត្តផ្សេងទៀតដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យផលិតផលថ្នាំជក់
- ចាប់យកវត្ថុតាង និងបិទស្លាកបោះត្រាលើវត្ថុតាងនៃបទល្មើស
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

នីតិវិធីនៃការធ្វើអធិការកិច្ចផលិតផលថ្នាំជក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

### មាត្រា ៣២.-

មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ ទទួលនីតិសម្បទាឲ្យពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់នេះ ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បែបបទ និងនីតិវិធីនៃការផ្ដល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

**មាត្រា ៣៣.-**

រាល់ប្រតិបត្តិការពិនិត្យបទល្មើសរបស់មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។ មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ មានសិទ្ធិស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់ថ្នាក់ និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៣៤.-**

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ត្រូវស្លៀកពាក់ឯកសណ្ឋាន និងមានបណ្ណសម្គាល់ខ្លួន ព្រមទាំងមានលិខិតអនុញ្ញាតឲ្យបំពេញបេសកកម្ម ។

ឯកសណ្ឋាន និងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ៣៥.-**

បុគ្គលដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ អាចធ្វើបណ្តឹងតវ៉ាក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ ទៅរដ្ឋមន្ត្រីក្រសួងសុខាភិបាល គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច ឬថ្ងៃដកហូត ។

រដ្ឋមន្ត្រីក្រសួងសុខាភិបាលត្រូវសម្រេចបណ្តឹងក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ គិតពីថ្ងៃទទួលពាក្យបណ្តឹង ។

ក្នុងករណីដែលបុគ្គលណាមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល បុគ្គលនោះមានសិទ្ធិធ្វើបណ្តឹងទៅតុលាការតាមនីតិវិធី ។

**មាត្រា ៣៦.-**

នៅពេលប្រតិបត្តិការអនុវត្តច្បាប់នេះ ក្នុងករណីវត្ថុតាងនៃបទល្មើសជាផលិតផលហាមឃាត់ ឬមានគ្រោះថ្នាក់ មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់មានសិទ្ធិស្នើសុំដីកាសម្រេចរបស់ព្រះរាជអាជ្ញា ដើម្បីធ្វើការបំផ្លាញចោលដោយអនុលោមតាមនីតិវិធីជាធរមាន ។

ការចំណាយលើការបំផ្លាញចោលវត្ថុតាងដូចមានចែងខាងលើ គឺជាបន្ទុករបស់ម្ចាស់វត្ថុតាងនៃបទល្មើស ។

**មាត្រា ៣៧.-**

ប្រាក់ពិន័យអន្តរការណ៍ត្រូវបង់ចូលថវិការដ្ឋ ។ រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់មន្ត្រី ដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសជាក់លាក់ណាមួយដែលចែងក្នុងច្បាប់នេះ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១១
## ទោសប្បញ្ញត្តិ

**មាត្រា ៣៨.-**

ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយលក់ និងប្រើប្រាស់ ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៨ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ២០ ០០០ ០០០ (ម្ភៃលាន) រៀល ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

**មាត្រា ៣៩.-**

ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយលក់ និងប្រើប្រាស់ ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ។ ក្នុងករណី ធ្លាប់ទទួលរងការផ្តន្ទាទោសពិន័យជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តបទល្មើស ដដែលនេះក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យទ្វេដង ។

**មាត្រា ៤០.-**

ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយលក់ និងប្រើប្រាស់ ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១០ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ២០ ០០០ ០០០ (ម្ភៃលាន) រៀល ។

ក្នុងករណីធ្លាប់ទទួលរងការផ្តន្ទាទោសពិន័យជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តបទល្មើសដដែលនេះក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យទ្វេដង ។

**មាត្រា ៤១.-**

ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយលក់ និងប្រើប្រាស់ ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៨ ០០០ ០០០ (ប្រាំបីលាន) រៀល ទៅ ៤០ ០០០ ០០០ (សែសិបលាន) រៀល ។

ក្នុងករណីធ្លាប់ទទួលរងការផ្តន្ទាទោសពិន័យជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តបទល្មើសដដែលនេះក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យទ្វេដង ។

**មាត្រា ៤២.-**

ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយលក់ និងប្រើប្រាស់ ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ។

ក្នុងករណីធ្លាប់ទទួលរងការផ្តន្ទាទោសពិន័យជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តបទល្មើសដដែលនេះក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យទ្វេដង ។

**មាត្រា ៤៣.-**

ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយលក់ និងប្រើប្រាស់ ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៨ ០០០ ០០០ (ប្រាំបីលាន) រៀល ទៅ ៤០ ០០០ ០០០ (សែសិបលាន) រៀល ។

ក្នុងករណីធ្លាប់ទទួលរងការផ្តន្ទាទោសពិន័យជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តបទល្មើសដដែលនេះក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យទ្វេដង ។

**មាត្រា ៤៤.-**

អំពើលក់ ឬចែកចាយផលិតផលថ្នាំជក់គ្រប់ប្រភេទដល់ជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ឬស្ត្រីដែលមានគភ៌ កាលបើគភ៌នោះត្រូវបានគេឃើញជាក់ស្តែង ឬកាលដែលខ្លួនបានដឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ១ (មួយ) ខែ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ១ ០០០ ០០០ (មួយលាន) រៀល ។

**មាត្រា ៤៥.-**

រាល់បរិមាណ ចំនួនបារី ឬផលិតផលថ្នាំជក់ដែលត្រូវបានបញ្ជត្តហាមឃាត់ដោយមាត្រា ១៦ នៃច្បាប់នេះ ត្រូវរឹបអូសដោយមន្ត្រីមានសមត្ថកិច្ច ។

**មាត្រា ៤៦.-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ១ ០០០ ០០០ (មួយលាន) រៀល ចំពោះអំពើលក់ ឬចែកចាយផលិតផលថ្នាំជក់គ្រប់ប្រភេទ នៅក្នុងបរិវេណនៃគ្រឹះស្ថានសិក្សា គ្រឹះស្ថានសុខាភិបាល សួនកុមារ គ្រឹះស្ថានសាសនា សារមន្ទីរ រមណីយដ្ឋានប្រវត្តិសាស្ត្រ កន្លែងហាត់ប្រាណ ស្ថានីយ ប្រេងឥន្ធនៈ និងកន្លែងងាយឆាបឆេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០ ០០០ (ពីរសែន) រៀល ទៅ ២ ០០០ ០០០ (ពីរលាន) រៀល ចំពោះអំពើលក់ផលិតផលថ្នាំជក់គ្រប់ប្រភេទតាមមធ្យោបាយមិនផ្ទាល់ តាមរយៈម៉ាស៊ីនលក់ដោយស្វ័យប្រវត្តិ តាមការបញ្ជាទិញតាមប្រៃសណីយ៍ និងតាមការបញ្ជាទិញតាមសេវាទូរគមនាគមន៍ផ្សេងៗ ។

**មាត្រា ៤៧.-**

នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៣៨ ដល់មាត្រា ៤៣ និងកថាខណ្ឌទី ២ មាត្រា ៤៦ នៃច្បាប់នេះ ។

នីតិបុគ្គលត្រូវពិន័យជាប្រាក់ទ្វេដង ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ ៖

១- ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

២- ការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រម-ព្រហ្មទណ្ឌ ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមព្រហ្មទណ្ឌ ។

៤- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមព្រហ្មទណ្ឌ ។

៥- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍) នៃក្រមព្រហ្ម-ទណ្ឌ ។

## ជំពូកទី ១២
## អន្តរប្បញ្ញត្តិ

**មាត្រា ៤៨.-**

បទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យផលិតផលថ្នាំជក់ ដែលនៅជាធរមាន នៅមានសុពលភាពរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១៣
## អវសានប្បញ្ញត្តិ

**មាត្រា ៤៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ២០១៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរល. ១៥០៥.៤៥៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ហត្ថលេខា**

**ម៉ម ប៊ុនហេង**

លេខ: ៤៦៥ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

នស/រកត/០៥១៥/៤០៤

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៥ នៃរដ្ឋសភា នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ ថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាព រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់ច្បាប់ស្តីពីថវិកាប្រចាំឆ្នាំ២០១៥ របស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** ដម្លើងថ្នាក់ដោយផ្លាស់ឋានន្តរសក្តិ ពីឋានន្តរសក្តិវរអភិបាល ទៅក្នុងឋានន្តរសក្តិឧត្តមអភិបាល នៃក្របខ័ណ្ឌអភិបាល ដល់មន្ត្រីរាជការចំនួន ២០រូប នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា សម្រាប់ឆ្នាំ២០១៣ ចាប់ពីខែមេសា ឆ្នាំ២០១៥ ៖

| | |
|---|---|
| ១-ឯកឧត្តម **គីម សារ៉ែត** | អត្តលេខ ០១៧៥ ពីឋានន្តរសក្តិវរអភិបាល ថ្នាក់លេខ៤ ទៅឋានន្តរសក្តិឧត្តមអភិបាល ថ្នាក់លេខ៦ |
| ២- ឯកឧត្តម **ឈុន ច័ន្ទបូរ៉ា** | អត្តលេខ ០០១២ ពីឋានន្តរសក្តិវរអភិបាល ថ្នាក់លេខ៥ ទៅឋានន្តរសក្តិឧត្តមអភិបាល ថ្នាក់លេខ៦ |
| ៣- ឯកឧត្តម **អ៊ុំ ប៊ុនធឿន** | អត្តលេខ ០០៨០ ពីឋានន្តរសក្តិវរអភិបាល ថ្នាក់លេខ៥ ទៅឋានន្តរសក្តិឧត្តមអភិបាល ថ្នាក់លេខ៦ |
| ៤- ឯកឧត្តម **ទូន សារ៉ាត្ន** | អត្តលេខ ០១៨៩ ពីឋានន្តរសក្តិវរអភិបាល ថ្នាក់លេខ៥ ទៅឋានន្តរសក្តិឧត្តមអភិបាល ថ្នាក់លេខ៦ |
| ៥- លោកជំទាវ **សេង សុមត្ថា** | អត្តលេខ ០០១៦ ពីឋានន្តរសក្តិវរអភិបាល ថ្នាក់លេខ៦ ទៅឋានន្តរសក្តិឧត្តមអភិបាល ថ្នាក់លេខ៦ |
| ៦- ឯកឧត្តម **ប៉ែន វិសូ** | អត្តលេខ ០១០៩ ពីឋានន្តរសក្តិវរអភិបាល ថ្នាក់លេខ៦ ទៅឋានន្តរសក្តិឧត្តមអភិបាល ថ្នាក់លេខ៦ |

៧- ឯកឧត្តម **ឈឹម ឃឿន** អត្តលេខ ០១៤៩ ពីឋានន្តរសក្តិវរអភិបាល ថ្នាក់លេខ៧
ទៅឋានន្តរសក្តិឧត្តមអភិបាល ថ្នាក់លេខ៦

៨- ឯកឧត្តម **ជា គីមហាន** អត្តលេខ ០១០៧ ពីឋានន្តរសក្តិវរអភិបាល ថ្នាក់លេខ៧
ទៅឋានន្តរសក្តិឧត្តមអភិបាល ថ្នាក់លេខ៦

៩- លោកជំទាវ **ចាន់ បូផាន** អត្តលេខ ០០៦៣ ពីឋានន្តរសក្តិវរអភិបាល ថ្នាក់លេខ៧
ទៅឋានន្តរសក្តិឧត្តមអភិបាល ថ្នាក់លេខ៦

១០- ឯកឧត្តម **សុន សុខហេង** អត្តលេខ ០១៥១ ពីឋានន្តរសក្តិវរអភិបាល ថ្នាក់លេខ៧
ទៅឋានន្តរសក្តិឧត្តមអភិបាល ថ្នាក់លេខ៦

១១- ឯកឧត្តម **ទេស សុផាណ្ណារ៉ា** អត្តលេខ ០២២២ ពីឋានន្តរសក្តិវរអភិបាល ថ្នាក់លេខ៧
ទៅឋានន្តរសក្តិឧត្តមអភិបាល ថ្នាក់លេខ៦

១២- ឯកឧត្តម **ឡាយ ម៉ិនម៉េង** អត្តលេខ ០១៥៣ ពីឋានន្តរសក្តិវរអភិបាល ថ្នាក់លេខ៧
ទៅឋានន្តរសក្តិឧត្តមអភិបាល ថ្នាក់លេខ៦

១៣- លោកជំទាវ **ទូច សុគន្ធ** អត្តលេខ ០១៥៤ ពីឋានន្តរសក្តិវរអភិបាល ថ្នាក់លេខ៧
ទៅឋានន្តរសក្តិឧត្តមអភិបាល ថ្នាក់លេខ៦

១៤- ឯកឧត្តម **ហ៊ឹម ចន្ថុនា** អត្តលេខ ០០៩០ ពីឋានន្តរសក្តិវរអភិបាល ថ្នាក់លេខ៧
ទៅឋានន្តរសក្តិឧត្តមអភិបាល ថ្នាក់លេខ៦

១៥- ឯកឧត្តម **ខិន សុផាត** អត្តលេខ ០១៣៥ ពីឋានន្តរសក្តិវរអភិបាល ថ្នាក់លេខ៧
ទៅឋានន្តរសក្តិឧត្តមអភិបាល ថ្នាក់លេខ៦

១៦- ឯកឧត្តម **អ៊ិន ម៉ិនអេង** អត្តលេខ ០២៩៦ ពីឋានន្តរសក្តិវរអភិបាល ថ្នាក់លេខ៧
ទៅឋានន្តរសក្តិឧត្តមអភិបាល ថ្នាក់លេខ៦

១៧- ឯកឧត្តម **សាត ពុធថាវី** អត្តលេខ ០០៨១ ពីឋានន្តរសក្តិវរអភិបាល ថ្នាក់លេខ៧
ទៅឋានន្តរសក្តិឧត្តមអភិបាល ថ្នាក់លេខ៦

១៨- ឯកឧត្តម **ម៉ែន ប្រាកដ** អត្តលេខ ០២២៣ ពីឋានន្តរសក្តិវរអភិបាល ថ្នាក់លេខ៧
ទៅឋានន្តរសក្តិឧត្តមអភិបាល ថ្នាក់លេខ៦

១៩- ឯកឧត្តម **ឯក សារន្ត** អត្តលេខ ០២៣៦ ពីឋានន្តរសក្តិវរអភិបាល ថ្នាក់លេខ៧
ទៅឋានន្តរសក្តិឧត្តមអភិបាល ថ្នាក់លេខ៦

២០- ឯកឧត្តម **ខាន់ ចន្ថុនៈ** អត្តលេខ ០១៣៣ ពីឋានន្តរសក្តិវរអភិបាល ថ្នាក់លេខ៧
ទៅឋានន្តរសក្តិឧត្តមអភិបាល ថ្នាក់លេខ៦

**មាត្រា២ :** សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

[illegible].១៥០៥.៤០៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៥*

លេខៈ ៥៤៣ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៥/៤០៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៥ នៃរដ្ឋសភា នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ ថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាព រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់ច្បាប់ស្តីពីថវិកាប្រចាំឆ្នាំ២០១៥ របស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ដម្លើងថ្នាក់មួយថ្នាក់ក្នុងឋានន្តរសក្តិឧត្តមអភិបាល នៃក្របខ័ណ្ឌអភិបាល ដល់មន្ត្រីរាជការចំនួន០៨រូប នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា សម្រាប់ឆ្នាំ២០១៣ ចាប់ពីខែមេសា ឆ្នាំ២០១៥៖

| | |
|---|---|
| ១- អ្នកអង្គម្ចាស់ **នរោត្តម ដារ៉ារ៉េត** | អត្តលេខ ០១៧៥ ពីថ្នាក់លេខ**២** ទៅថ្នាក់លេខ**១** |
| ២- ឯកឧត្តម **កែ កេតនិន** | អត្តលេខ ០០០៩ ពីថ្នាក់លេខ**៥** ទៅថ្នាក់លេខ**៤** |
| ៣- ឯកឧត្តម **ហង្ស វិចិត្រ** | អត្តលេខ ០១១៧ ពីថ្នាក់លេខ**៥** ទៅថ្នាក់លេខ**៤** |
| ៤- ឯកឧត្តម **កែវ ពិសិដ្ឋ** | អត្តលេខ ១១៦៨ ពីថ្នាក់លេខ**៥** ទៅថ្នាក់លេខ**៤** |
| ៥- ឯកឧត្តម **អ៊ិច សំអុល** | អត្តលេខ ០១០១ ពីថ្នាក់លេខ**៥** ទៅថ្នាក់លេខ**៤** |
| ៦- ឯកឧត្តម **អៀ ចាន់ឌី** | អត្តលេខ ០១២៣ ពីថ្នាក់លេខ**៥** ទៅថ្នាក់លេខ**៤** |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៧- ឯកឧត្តម **ព្រហ្ម ទិរៈ** អត្តលេខ ០០១៣ ពីថ្នាក់លេខ**៥** ទៅថ្នាក់លេខ៤

៨- ឯកឧត្តម **ហួត ពៅ** អត្តលេខ ០០១៤ ពីថ្នាក់លេខ**៥** ទៅថ្នាក់លេខ៤

**មាត្រា២ :** **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.០៥១៥.៤០៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៥*

លេខ: ៤៨៧ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ .ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៥/៤០៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៥ នៃរដ្ឋសភា នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ ថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ច្បាប់ស្តីពីថវិកាប្រចាំឆ្នាំ២០១៥ របស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីប្រកាសលេខ០២២ រ.ស ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥ របស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីស្នើសុំរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា។

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង និងផ្តល់ឋានៈជាលេខាធិការ នៃការិយាល័យថ្នាក់ដឹកនាំតំណាងរាស្ត្រ នៃគណបក្សប្រជាជនកម្ពុជា ក្នុងនីតិកាលទី៥ នៃរដ្ឋសភា ៖

១- ឯកឧត្តម **ជា តារា** មានឋានៈស្មើ **អគ្គនាយក**
២- ឯកឧត្តម **គុង វណ្ណៈ** មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

**មាត្រា២ :** **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧៣៣.១៥០៥.៤០៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៥*

លេខៈ ៤៦៨ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៥/៤០៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៥ នៃរដ្ឋសភា នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ ថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ច្បាប់ស្តីពីថវិកាប្រចាំឆ្នាំ២០១៥ របស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រងយល់សេចក្តីប្រកាសលេខ០២២ រ.ស ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥ របស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីស្នើសុំរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង និងផ្តល់ឋានៈជាលេខាធិការ នៃការិយាល័យថ្នាក់ដឹកនាំតំណាងរាស្ត្រ នៃគណបក្សសង្គ្រោះជាតិ នីតិកាលទី៥ នៃរដ្ឋសភា ៖

១- លោកជំទាវ **តែ ម៉ានីណា** មានឋានៈស្មើ **អគ្គនាយក**
២- ឯកឧត្តម **អោក អមរី** មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

**មាត្រា២ :** សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៥០៥.៤១០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១៥

លេខៈ ៤៦៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៥១៥/៤០៧

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **ប៊ូ សុវណ្ណរ៉េត** ជានាយកខុទ្ទកាល័យអនុប្រធានទី២ ព្រឹទ្ធសភា នីតិកាលទី៣ មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៥០៥.៤១១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៥

លេខ: ៤៧៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៥/៤៣២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា)

**ត្រាស់បង្គាប់**

**តែងតាំង :**

**លោក ឡុង ឌីណាល់**

**ជា**

**ឧកញ៉ា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧.១៥០៥.៤៣៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៥*

លេខ: ៤៧៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៥/៤៣៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា)

## ត្រាស់បង្គាប់

តែងតាំង :

លោក ឈួន ចេតនា

ជា

ឧកញ៉ា

៣៧៧.១៥០៥.៤៣២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៥

លេខ: ៤៧៤ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ. ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

នស/រកត/០៥១៥/៤៣៤

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១ :** តែងតាំងជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី៣ មានឋានៈស្មើ **រដ្ឋលេខាធិការ** ចំនួន ០២រូប :

១- ឯកឧត្តម **លីច យិន**

២- ឯកឧត្តម **លី ជុនគ័ង**

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.១៥០៥.៤៣៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៥

លេខ: ៤៧០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៥/៤៣៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា)

## ត្រាស់បង្គាប់

**តែងតាំង :**

**លោក ចាប ហុងលី**

**ជា**

**ឧកញ៉ា**

៣៖ស.១៥០៥.៤៣៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១៥

លេខ: ៤៧៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៥/៤៣៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហរាស គម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**
ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា)

**ត្រាស់បង្គាប់**

**តែងតាំង :**

លោក **ប៉ែន ស៊ីនេត (គាត់)**

**ជា**

**ឧកញ៉ា**

ពសល.១៥០៥.៤៣៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១៥*

លេខ: ៤៧២ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី២២ ខែឧសភាឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៥/៤៣៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា)

## ត្រាស់បង្គាប់

**តែងតាំង :**

**លោក ជាម យុនណាត**

**ជា**

**ឧកញ៉ា**

៧៩ល.១៥០៥.៤៤០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥*

លេខ:៤៧៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៥/៤៤៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្ទេរបញ្ចូល ជាករណីពិសេស លោកស្រី **ឃឿង ឃឿង** ពីឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៤ មកឋានន្តរស័ក្តិអនុមន្ត្រីថ្នាក់លេខ១៤ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៤៥៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

៧រល.១៥០៥.៤៤៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៥*

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៥/៤៤៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តម្លើងឋានន្តរស័ក្តិ ជាករណីពិសេស ដល់មន្ត្រីរាជការចំនួន ០៤ រូប ពីឋានន្តរស័ក្តិវរមន្ត្រី មកឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ៖

១-ឯកឧត្តម **ហ៊ិន យុទ្ធនា** ពីវរមន្ត្រី ថ្នាក់លេខ ៥ មកឧត្តមមន្ត្រី ថ្នាក់លេខ ៦
២-ឯកឧត្តម **មុនី ធីរៈ** ពីវរមន្ត្រី ថ្នាក់លេខ ៨ មកឧត្តមមន្ត្រី ថ្នាក់លេខ ៦
៣-ឯកឧត្តម **ត្រី សុខហេង** ពីវរមន្ត្រី ថ្នាក់លេខ ៩ មកឧត្តមមន្ត្រី ថ្នាក់លេខ ៦
៤-ឯកឧត្តម **ស្វរ តីម៉ា** ពីវរមន្ត្រី ថ្នាក់លេខ ៩ មកឧត្តមមន្ត្រី ថ្នាក់លេខ ៦ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

[illegible].១៥០៥.៤៤៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៥*

លេខ: ៤៥៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៥១៥/៤៤៤

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ដល់វរសេនីយ៍ឯក **សេក រស់** អត្តលេខ ០១០៥២២ នាយទាហានថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៤៤៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

ពាសស.១៥០៥.៤៤៨

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៥*

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៥/៤៤៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ ដល់ នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ៖

**ក-ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ**

| | | | |
|---|---|---|---|
| ១-ឧត្តមសេនីយ៍ត្រី | **ជួង** | **ចន្ទណារិទ្ធ** | អត្តលេខ ០១៨៦១៦ |
| ២-ឧត្តមសេនីយ៍ត្រី | **គុប** | **សារ៉ុម** | អត្តលេខ ០០០៩១៣ |
| ៣-ឧត្តមសេនីយ៍ត្រី | **គង់** | **ឆេងចន** | អត្តលេខ ០០២៨១៧ |
| ៤-ឧត្តមសេនីយ៍ត្រី | **សោម** | **សាមិទ្ធ** | អត្តលេខ ០០០៩៥០ |
| ៥-ឧត្តមសេនីយ៍ត្រី | **សំរិទ្ធ** | **រាំង** | អត្តលេខ ០០១១៧១ |
| ៦-ឧត្តមសេនីយ៍ត្រី | **មុំ** | **សាម៉ីឌី** | អត្តលេខ ០០២៣១០ |
| ៧-ឧត្តមសេនីយ៍ត្រី | **មាស** | **ស៊ុំ** | អត្តលេខ ០០៤៩៧៦ |
| ៨-ឧត្តមសេនីយ៍ត្រី | **ហាក់** | **ឆេងហួត** | អត្តលេខ ១៣២៣០៣ |
| ៩-ឧត្តមសេនីយ៍ត្រី | **ទេព** | **រួន** | អត្តលេខ ០០១៤១៩ |
| ១០-ឧត្តមសេនីយ៍ត្រី | **អ៊ិន** | **សុខាឧត្តរី** | អត្តលេខ ០០១០៥១ |
| ១១-ឧត្តមសេនីយ៍ត្រី | **អឿ** | **ប៊ុនធឿន** | អត្តលេខ ០០០៨៥២ |
| ១២-ឧត្តមសេនីយ៍ត្រី | **ឃួន** | **សំខាន់** | អត្តលេខ ០១០៣៣៥ |
| ១៣-ឧត្តមសេនីយ៍ត្រី | **ម៉ាន់** | **ប៉េងអៀង** | អត្តលេខ ០០៤២២៨ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះបរមរាជវាំង

១៤-ឧត្តមសេនីយ៍ត្រី **សាន សារឿន** អត្តលេខ ០០៩៤៤០

**ខ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី**

១-វរសេនីយ៍ឯក **ឯក ស៊ីធឿន** អត្តលេខ ០០០៤២០
២-វរសេនីយ៍ឯក **ម៉ាយ ម៉ើន** អត្តលេខ ០០១០៦៧
៣-វរសេនីយ៍ឯក **យៀប ម៉ៅ** អត្តលេខ ០០១០៦៣
៤-វរសេនីយ៍ឯក **ពេជ្រ សុមាលី** អត្តលេខ ០០១០៦៥
៥-វរសេនីយ៍ឯក **ម៉ែន មាស** អត្តលេខ ០១០៨៦៧
៦-វរសេនីយ៍ឯក **ហង្ស ម៉ុនធឿន** អត្តលេខ ០០៤៩៥៣
៧-វរសេនីយ៍ឯក **រម្យ ហាយ** អត្តលេខ ០០២៦៦០
៨-វរសេនីយ៍ឯក **នី សុចត្តនា** អត្តលេខ ០០៤៩៦១
៩-វរសេនីយ៍ឯក **ឡេង ថារិទ្ធ** អត្តលេខ ០១៨៦០០
១០-វរសេនីយ៍ឯក **ជា សុផល** អត្តលេខ ០០៩៨៤៦
១១-វរសេនីយ៍ឯក **ស៊ុន សាម៉ន** អត្តលេខ ០០៩៨០៧
១២-វរសេនីយ៍ឯក **ម៉ុន ថា** អត្តលេខ ០០០៩៣១
១៣-វរសេនីយ៍ឯក **ជាតិ ប៉ូលីន** អត្តលេខ ០២៥៦៦៤
១៤-វរសេនីយ៍ឯក **ចាន់ ចិន្តា** អត្តលេខ ០០២៨៥៦
១៥-វរសេនីយ៍ឯក **សេដ្ឋ សំអុល** អត្តលេខ ០០៣៦១៥
១៦-វរសេនីយ៍ឯក **អ៊ុក មិត្ត** អត្តលេខ ០០៣២០៥
១៧-វរសេនីយ៍ឯក **នួន ម៉ារី** អត្តលេខ ០០១០៤៩
១៨-វរសេនីយ៍ឯក **ទេព សុផល** អត្តលេខ ០០៣០៤៩
១៩-វរសេនីយ៍ឯក **តាំង ម៉ុនហួរ** អត្តលេខ ០០៤៧៣៧
២០-វរសេនីយ៍ឯក **អ៊ី ចាសនា** អត្តលេខ ២៣២១៣៣
២១-វរសេនីយ៍ឯក **ម៉ា សិទ្ធ** អត្តលេខ ០០៩៦៧៣
២២-វរសេនីយ៍ឯក **មាស ចណ្ណារី** អត្តលេខ ០០៩២៧១
២៣-វរសេនីយ៍ឯក **គីម ណារ៉ាត់** អត្តលេខ ០០១២១០
២៤-វរសេនីយ៍ឯក **សៅ សំអឿន** អត្តលេខ ០០២២៥៥
២៥-វរសេនីយ៍ឯក **គង់ សាម៉ន** អត្តលេខ ០០៣៨៥០
២៦-វរសេនីយ៍ឯក **យឹម ចាសនា** អត្តលេខ ០០៣៤៨៥

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត/០៥១៥/៤៤៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៥

២/២

លេខ: ៤៥៧ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណាវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ (Kampong Speu Institute of Technology ) សរសេរកាត់ជាភាសាខ្មែរ **វ.ប.ក.ស.** និងជាភាសាអង់គ្លេស K.S.I.T ។

**មាត្រា២.-**

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំ យុវជន និងកីឡា។

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ មានទីតាំងស្ថិតនៅភូមិអូរអង្គុំ ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។

**មាត្រា៣.-**

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ មានភារកិច្ចដូចខាងក្រោម៖

- បណ្តុះបណ្តាលអ្នកជំនាញបច្ចេកទេសកម្រិតមធ្យម និងអ្នកបច្ចេកទេសកម្រិតឧត្តម
- ស្រាវជ្រាវ និងធ្វើសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សាជាតិ និងអន្តរជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា
- លើកកម្ពស់សមត្ថភាពជំនាញបច្ចេកទេសដល់គ្រូបង្រៀន និងគ្រូបច្ចេកទេស
- អភិវឌ្ឍកម្មវិធីសិក្សាឲ្យស្របតាមតម្រូវការទីផ្សារការងារ ស្តង់ដារសមត្ថភាព និងកម្រិតគុណវុឌ្ឍិជាតិ
- ជ្រើសរើសសិស្ស និស្សិតឲ្យចូលរៀន ស្របតាមគោលការណ៍កំណត់
- កសាងផែនការអភិវឌ្ឍន៍រយៈពេលខ្លី មធ្យម និងវែង
- គ្រប់គ្រងមន្ត្រីរាជការ បុគ្គលិក គ្រូបង្រៀន កម្មករ និស្សិត និងទ្រព្យសម្បត្តិ។

**មាត្រា៤.-**

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ បណ្តុះបណ្តាលនិស្សិតកម្រិតបរិញ្ញាបត្ររង(១២+២ ឬ ៩+៣+២) និងបរិញ្ញាបត្រ(២+២)លើមុខជំនាញ វិស្វកម្មសំណង់ស៊ីវិល វិស្វកម្មអគ្គិសនី វិស្វកម្មអេឡិចត្រូនិច វិស្វកម្មមេកានិច វិស្វកម្មគីមីចំណីអាហារ វិទ្យាសាស្ត្រសត្វ វិទ្យាសាស្ត្រដំណាំ វិទ្យាសាស្ត្រកុំព្យូទ័រ កុំព្យូទ័រពាណិជ្ជកម្ម គ្រប់គ្រងទេសចរណ៍ និងសណ្ឋាគារ គ្រប់គ្រងធុរកិច្ច គណនេយ្យ និងឡូជីស្ទីក ។

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ អាចបើកមុខជំនាញថ្មី ឬ កម្រិតបណ្តុះបណ្តាលបន្តដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៥.-**

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ មាន១១ ដេប៉ាតឺម៉ង់ ៖

- ដេប៉ាតឺម៉ង់វិស្វកម្មសំណង់ស៊ីវិល
- ដេប៉ាតឺម៉ង់វិស្វកម្មអគ្គិសនី
- ដេប៉ាតឺម៉ង់វិស្វកម្មអេឡិចត្រូនិច
- ដេប៉ាតឺម៉ង់វិស្វកម្មមេកានិច

- ដេប៉ាតឺម៉ង់វិស្វកម្មគីមីចំណីអាហារ
- ដេប៉ាតឺម៉ង់វិទ្យាសាស្ត្រកុំព្យូទ័រ
- ដេប៉ាតឺម៉ង់កុំព្យូទ័រពាណិជ្ជកម្ម
- ដេប៉ាតឺម៉ង់បសុវប្បកម្ម
- ដេប៉ាតឺម៉ង់កេ្សត្រសាស្ត្រ
- ដេប៉ាតឺម៉ង់ទេសចរណ៍ និងសណ្ឋាគារ
- ដេប៉ាតឺម៉ង់គ្រប់គ្រងធុរកិច្ច។

ទៅអនាគត វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ អាចបើកមហាវិទ្យាល័យ ដេប៉ាតឺម៉ង់ កម្រិត ឬ ប្រភេទបណ្តុះបណ្តាលផ្សេងទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៦.-**

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការ យុទ្ធសាស្ត្រ កម្មវិធី និងការងារពាក់ព័ន្ធផ្សេងៗទៀតរបស់វិទ្យាស្ថាន។

**មាត្រា៧.-**

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ ត្រូវដឹកនាំដោយនាយកមួយរូប ដែលមានឋានៈស្មើប្រធាននាយកដ្ឋាន និងនាយករងមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៨.-**

និស្សិតដែលបានរៀនចប់តាមកម្មវិធីសិក្សារបស់វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ និងទទួលបានជោគជ័យក្នុងការបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងមុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះត្រូវផ្តល់ឲ្យដោយវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ ផ្អែកលើបញ្ជីឈ្មោះនិស្សិតបញ្ចប់ការសិក្សាជាប់ជាស្ថាពរ ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៩.-**

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ មានប្រភពធនធានដូចខាងក្រោម៖
- ថវិកាជាតិដែលជាឧបសម្ព័ន្ធក្នុងកញ្ចប់ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា
- ថវិកាដែលស្ថិតក្នុងកញ្ចប់មូលនិធិរបស់វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ
- ថវិកាដែលទទួលបានពីការបង់ថ្លៃបណ្តុះបណ្តាល
- ប្រភពផ្សេងៗទៀត។

វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀតពីប្រភពខាងក្នុង ឬ ក្រៅប្រទេសសម្រាប់បម្រើសេចក្តីត្រូវការរបស់ខ្លួន។

**មាត្រា១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ហង់ ជួន ណារ៉ុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៦៣ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៣៣៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១.**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាពីជំពូក៦១ (សេវាកម្ម) ចំនួន៩៥ ០០០ ០០០រៀល មកជំពូក៦០ (ការទិញ)ចំនួន៩៥ ០០០ ០០០រៀល ជូនក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ។

**មាត្រា២.**

ការបែងចែកឥណទានថវិកាផ្ទេរក្នុងជំពូកនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការចំណាយជាក់ស្តែងរបស់ក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ។

**មាត្រា៣.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡាត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៦៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅ
## របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៤/១១៣៦ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ដែលហៅកាត់ថាអគ្គលេខាធិការដ្ឋាន **ក.ជ.វ.ប.**។

## ជំពូកទី២
## តួនាទីនិងភារកិច្ច

**មាត្រា២ ..**

អគ្គលេខាធិការដ្ឋាននៃ **គ.ជ.វ.ប.** មានតួនាទីជាសេនាធិការជូន **គ.ជ.វ.ប.** និងមានភារកិច្ចដូចខាងក្រោមៈ

- គ្រប់គ្រងកិច្ចការរដ្ឋបាល ផែនការ ហិរញ្ញវត្ថុ និងបច្ចេកទេសដើម្បីធានាបាននូវការប្រព្រឹត្តទៅប្រកបដោយនិរន្តរភាពរបស់ **គ.ជ.វ.ប.**
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងគ្រប់គ្រងហិរញ្ញវត្ថុនិងធនធានរបស់ **គ.ជ.វ.ប.**
- រៀបចំ រក្សា និងផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងកម្មវិធីដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិ
- ពិនិត្យ តាមដាន វាយតម្លៃ និងជំរុញការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត យុទ្ធសាស្ត្រ គោលនយោបាយ ផែនការជាតិ និងការសម្របសម្រួលដើម្បីលើកកម្ពស់ការប្រើប្រាស់ធនធានជាតិសម្រាប់ការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- រៀបចំនិងបង្កើតកម្មវិធីនិងសេវានានាដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការជាតិសម្រាប់ការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- លើកសំណើសុំពិនិត្យនិងកែលម្អច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងកម្មវិធីអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា-ជាតិជូន **គ.ជ.វ.ប.**
- រៀបចំការប្រជុំ សន្និសីទ សិក្ខាសាលា ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិ
- ជំរុញនិងលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់ការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- សម្របសម្រួល លើកកម្ពស់ស្មាដៃនិងការងារអន្តរកម្មជាបណ្តាញក្នុងចំណោមស្ថាប័នរដ្ឋ ស្ថាប័នឯកជន សង្គមស៊ីវិល អង្គការជាតិ អង្គការអន្តរជាតិ និងអ្នកដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ប្រមូល ចងក្រង កែច្នៃ ប្រើប្រាស់ និងផ្សព្វផ្សាយព័ត៌មានអំពីស្ថានភាពនៃការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ការប្រើប្រាស់មូលដ្ឋាននិងបរិក្ខារវិទ្យាសាស្ត្រ និងលទ្ធផលនៃការស្រាវជ្រាវនិងការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ប្រមូលនិងផ្តល់ព័ត៌មានពីការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាដែលសំខាន់ៗ

- ធ្វើរបាយការណ៍ជូន **ក.ជ.ទ.ប.** និងស្ថាប័នពាក់ព័ន្ធ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែល **ក.ជ.ទ.ប.** ប្រគល់ជូន។

## ជំពូកទី៣
## រចនាសម្ព័ន្ធនិងការគ្រប់គ្រង

**មាត្រា៣ .-**

អគ្គលេខាធិការដ្ឋាននៃ **ក.ជ.ទ.ប.** មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- នាយកដ្ឋានគោលនយោបាយ ផែនការ រដ្ឋបាល ហិរញ្ញវត្ថុ និងព័ត៌មានវិទ្យា
- នាយកដ្ឋានសហប្រតិបត្តិការនិងការអភិវឌ្ឍធនធានមនុស្ស
- នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធនិងកម្មវិធីស្រាវជ្រាវនិងអភិវឌ្ឍជាតិ
- នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

អង្គការលេខនៃអគ្គលេខាធិការដ្ឋាន **ក.ជ.ទ.ប.** ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៤ .-**

នាយកដ្ឋាននីមួយៗមានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់ ហើយត្រូវដឹកនាំ និងគ្រប់គ្រងដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានទាំងអស់នេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងផែនការ។

**មាត្រា៥ .-**

អគ្គលេខាធិការដ្ឋាននៃ **ក.ជ.ទ.ប.** មានមន្ត្រីបម្រើការមកពីក្រសួងផែនការ និងមន្ត្រីរាជការនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈផ្សេងទៀត។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាន **ក.ជ.ទ.ប.** អាចមានទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការ និងបុគ្គលិកជាប់កិច្ចសន្យាដើម្បីជួយបំពេញការងាររបស់ខ្លួន។

## ជំពូកទី៤
## តួនាទីនិងភារកិច្ចរបស់នាយកដ្ឋាននីមួយៗ

**មាត្រា៦ .-**

**នាយកដ្ឋានគោលនយោបាយ ផែនការ រដ្ឋបាល ហិរញ្ញវត្ថុ និងព័ត៌មានវិទ្យា មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖**

- សម្របសម្រួលនិងរៀបចំសេចក្ដីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព កម្មវិធី និងយន្តការផ្សេងៗពាក់ព័ន្ធនឹងការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិ សម្រាប់ដាក់ជូន **ក.ជ.ទ.ប.** ពិនិត្យនិងសម្រេច/.../

- រក្សា ផ្សព្វផ្សាយ និងជំរុញការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងកម្មវិធីអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិ
- សម្របសម្រួលការងារនិងការកំណត់ធនធានការកសាង និងអនុវត្តផែនការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យារបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ធ្វើអង្កេត ជំរឿន និងវិភាគវាយតម្លៃលើកម្លាំងពលកម្ម(សមត្ថភាពចំណេះដឹង) និងប្រភពធនធានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាសម្រាប់រៀបចំធ្វើគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងកម្មវិធីអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិ
- បំពេញការងាររដ្ឋបាលនិងធានានិរន្តរភាពការងាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.វ.ប.**
- រៀបចំនិងចាត់ចែងកិច្ចប្រជុំរបស់ **គ.ជ.វ.ប.** និងធ្វើរបាយការណ៍នៃកិច្ចប្រជុំនេះ
- ធ្វើរបាយការណ៍បូកសរុបអំពីសកម្មភាពនិងលទ្ធផលការងារនៃអគ្គលេខាធិការដ្ឋាន **គ.ជ.វ.ប.**
- គ្រប់គ្រងចំណូល ចំណាយ និងលើកគម្រោងថវិកាប្រចាំឆ្នាំរបស់ **គ.ជ.វ.ប.**
- រៀបចំបង្កើត ប្រើប្រាស់ និងគ្រប់គ្រងមូលនិធិសម្រាប់អភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- គ្រប់គ្រងមន្ត្រីរាជការនិងបុគ្គលិកក្នុងអគ្គលេខាធិការដ្ឋាន
- សម្របសម្រួល លើកទឹកចិត្តនិងលើកកម្ពស់ស្នាដៃនិងការងារអន្តរកម្មជាបណ្តាញក្នុងចំណោមស្ថាប័នរដ្ឋ ស្ថាប័នឯកជន សង្គមស៊ីវិល អង្គការជាតិ អង្គការអន្តរជាតិ និងអ្នកដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ផ្គត់ផ្គង់និងរៀបចំសម្ភារៈ បរិក្ខារ និងគ្រប់គ្រងបញ្ជីសារពើភណ្ឌចលនទ្រព្យនិងអចលន-ទ្រព្យរបស់អគ្គលេខាធិការដ្ឋាន
- រៀបចំផែនការសកម្មភាពរបស់អគ្គលេខាធិការដ្ឋានសម្រាប់រយៈពេលខ្លី មធ្យម និងវែង
- សម្របសម្រួល ចងក្រង និងបូកសរុបការងារពាក់ព័ន្ធនឹងការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាដាក់ជូន **គ.ជ.វ.ប.** ដើម្បីពិនិត្យនិងសម្រេច
- បង្កើតនិងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គាំទ្រទំនាក់ទំនង និងការងាររបស់អគ្គលេខា-ធិការដ្ឋាន
- បង្កើត គ្រប់គ្រង និងសម្រួលការប្រើប្រាស់មូលទិន្នន័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងប្រព័ន្ធកម្មវិធីស្រាវជ្រាវនិងអភិវឌ្ឍជាតិ
- ប្រមូល ចងក្រង រក្សាទុក និងផ្សព្វផ្សាយព័ត៌មានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

- ប្រមូល កែច្នៃ វិភាគ និងផ្សព្វផ្សាយលទ្ធផលជំរឿន អង្កេតដែលទាក់ទងនឹងវិស័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- បង្កើតនិងកែលម្អគេហទំព័រស្តីពីវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំអំពីសកម្មភាពនិងលទ្ធផលការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន **គ.ជ.វ.ប.** ប្រគល់ជូន។

**មាត្រា៧ .-**

**នាយកដ្ឋានសហប្រតិបត្តិការនិងការអភិវឌ្ឍធនធានមនុស្ស មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖**

- បង្កើតបណ្តាញសហប្រតិបត្តិការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិនិងអន្តរជាតិ
- ប្រមូល និងផ្តល់ព័ត៌មានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា គោលនយោបាយវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៃបណ្តាប្រទេសជឿនលឿន ជូនអង្គភាពរដ្ឋ និងឯកជនដែលពាក់ព័ន្ធ
- សម្របសម្រួលធនធាននិងតម្រូវការសម្រាប់អភិវឌ្ឍកិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- រៀបចំ ដំណើរការ និងគ្រប់គ្រងកម្មវិធីស្រាវជ្រាវរួមជាមួយអន្តរជាតិ
- សិក្សា ស្រាវជ្រាវ និងសម្របសម្រួលតម្រូវការប្រើប្រាស់អ្នកវិទ្យាសាស្ត្រនិងវិស្វករពីបណ្តាប្រទេសជឿនលឿន
- ធ្វើការសិក្សា ស្រាវជ្រាវ និងសម្របសម្រួលតម្រូវការ និងការផ្គត់ផ្គង់ធនធានមនុស្សផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ធ្វើផែនការសម្រាប់ការអភិវឌ្ឍធនធានមនុស្ស ការកសាងសមត្ថភាព និងរៀបចំកម្មវិធីបណ្តុះបណ្តាលទាក់ទងនឹងផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាក្នុងនិងក្រៅប្រទេស
- សម្របសម្រួលជាមួយបណ្តាប្រទេសជឿនលឿនលើវិស័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាក្នុងការស្នើសុំការបណ្តុះបណ្តាលនិងចែករំលែកបទពិសោធ
- ឃោសនានិងផ្សព្វផ្សាយជាសាធារណៈពីសារៈសំខាន់នៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានិងជួយជំរុញការចូលរួម
- សម្របសម្រួល គ្រប់គ្រង និងចាត់ចែងធនធានមនុស្សសម្រាប់វិស័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំអំពីសកម្មភាពនិងលទ្ធផលការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន **គ.ជ.វ.ប.** ប្រគល់ជូន។

**មាត្រា៨ .-**

**នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធនិងកម្មវិធីស្រាវជ្រាវនិងអភិវឌ្ឍជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖**

- សិក្សា ស្រាវជ្រាវ និងសម្របសម្រួលតម្រូវការ និងការផ្គត់ផ្គង់មជ្ឈមណ្ឌលនិងបរិក្ខារស្រាវជ្រាវនិងអភិវឌ្ឍជាតិ
- ប្រមូល ចងក្រង ផ្សព្វផ្សាយ ព័ត៌មានមជ្ឈមណ្ឌល និងបរិក្ខារស្រាវជ្រាវនិងអភិវឌ្ឍ និងសម្រួលការប្រើប្រាស់
- សម្របសម្រួល វាយតម្លៃ និងបង្កើតកម្មវិធីស្រាវជ្រាវនិងអភិវឌ្ឍជាតិ
- ប្រមូលទិន្នន័យកម្មវិធីស្រាវជ្រាវនិងអភិវឌ្ឍពីក្រសួងស្ថាប័នពាក់ព័ន្ធ និងបណ្តាផ្នែកអនុវត្តកម្មវិធីស្រាវជ្រាវនិងអភិវឌ្ឍដើម្បីវិភាគ វាយតម្លៃ កំណត់ទិសដៅ និងផ្សព្វផ្សាយ
- សម្របសម្រួលនិងជួយជំរុញពាណិជ្ជូបនីយកម្មលទ្ធផលនៃការស្រាវជ្រាវនិងការអភិវឌ្ឍ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំអំពីសកម្មភាពនិងលទ្ធផលការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន **ក.ជ.វ.ប.** ប្រគល់ជូន។

**មាត្រា៩ .-**

នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាព និងកំណត់សូចនាករដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព កម្មវិធីអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព កម្មវិធីអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិ
- រៀបចំរបាយការណ៍នៃការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ និងលើកជាអនុសាសន៍ជូន **ក.ជ.វ.ប.** ដើម្បីពិនិត្យនិងសម្រេច
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើបុគ្គលនិងស្ថាប័នដែលមានស្នាដៃក្នុងការអភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងលើកជាសំណើជូន **ក.ជ.វ.ប.** ដើម្បីពិនិត្យនិងសម្រេចការលើកទឹកចិត្ត
- ផ្សព្វផ្សាយលទ្ធផលនៃការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃដល់ក្រសួង ស្ថាប័ន និងបុគ្គលដែលពាក់ព័ន្ធ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំអំពីសកម្មភាពនិងលទ្ធផលការងាររបស់ខ្លួន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាន**ក.ជ.វ.ប.**ប្រគល់ជូន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ**

**នៃអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១៥**

**ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ**

**របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា**

**អង្គការលេខនៃអគ្គលេខាធិការដ្ឋាន ក.ជ.វ.ប.**



# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៥១៧ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

## សម្រេច

**មាត្រា១.** បំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការចំនួន ១៥រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក- មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ**

| | | |
|---|---|---|
| ១- | លោក **ហួច ស៊ុនថាន** | ប្រធាននាយកដ្ឋានគ្រប់គ្រងនិងអភិរក្សធនធានទឹក |
| ២- | លោក **យិន សាវុធ** | ប្រធាននាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ |
| ៣- | លោក **ខួន ពេជ្រ** | ប្រធាននាយកដ្ឋានទឹកស្អាត និងអនាម័យ |
| ៤- | លោក **អ៊ុច ហ៊ីង** | ប្រធានមជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ និងឧតុនិយម |
| ៥- | លោក **ហ៊ុយ វ៉ាន់ថា** | ប្រធាននាយកដ្ឋានសហគមន៍កសិករប្រើប្រាស់ទឹក |
| ៦- | លោក **ហាក់ សុជាតិ** | ប្រធាននាយកដ្ឋាន |
| ៧- | លោក **អ៊ូ សុផាណា** | ប្រធាននាយកដ្ឋាន |
| ៨- | លោក **ឈាង ហុង** | ប្រធាននាយកដ្ឋាន |
| ៩- | លោក **ស៊ិន សំណាង** | អនុប្រធានក្តាប់រួមនាយកដ្ឋាន |
| ១០- | លោក **គីម សីហា** | អនុប្រធាននាយកដ្ឋាន |
| ១១- | លោក **គេម ស៊ា** | អនុប្រធាននាយកដ្ឋាន |
| ១២- | លោកស្រី **ទេស សុជាទី** | អនុប្រធាននាយកដ្ឋាន |

១៣- លោក **សំឯល ហាគីម** អនុប្រធាននាយកដ្ឋាន

**ខ- មេដាយសុវត្ថារា ថ្នាក់ សេនា**

១- លោកជំទាវ **ខ៊ាន់ ចាន់ថូ** អនុរដ្ឋលេខាធិការ

២- ឯកឧត្តម **អាន ពេជ្រហត្ថដា** អគ្គលេខាធិការរង

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៧៥ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការសម្រួលភារកិច្ចមន្ត្រីនគរបាលជាតិកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១** : សម្រួលភារកិច្ចលោកឧត្ដមសេនីយ៍ឯក **គឹម ចាន់នី** អត្តលេខ ០០៦៧ ពីអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ទៅជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើអគ្គនាយករង ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៥៤៦ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាល ខេត្តកោះកុង

## សម្រេច

**មាត្រា ១.**-បំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០៥គ្រឿង ជូនសប្បុរសជន ចំនួន ០៥រូប ដែលមានស្នាដៃល្អក្នុងការ ចូលរួមជួយកសាងអភិវឌ្ឍន៍ភូមិ-ឃុំ នានាក្នុងខេត្តកោះកុង កន្លងមក ដូចមានរាយនាមខាងក្រោម៖

១- ឧបាសិកា **អ៊ុំ** **គីមសួន** សប្បុរសជន

២- លោក **អ៊ូច** **ឌូច** សប្បុរសជន

៣- លោក **ឡៅ** **ប៊ុនខេង** សប្បុរសជន

៤- លោក **ឌិត** **សុជាតិ** សប្បុរសជន

៥- លោក **គ្រី** **ប៊ុនថា** សប្បុរសជន

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តកោះកុង និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែ ឧសភា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៧៣ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យ លេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**មាត្រា ១:** តែងតាំងលោកសាស្ត្រាចារ្យមហាបរិញ្ញា **ឈាង សេនា** ជាព្រឹទ្ធបុរសមហាវិទ្យាល័យឱសថសាស្ត្រ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល បន្ទាប់ពីលោកស្រីសាស្ត្រាចារ្យ **សាន់ សុជីវី** ចូលនិវត្តន៍ ។

**មាត្រា ២:** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៥៧៨...អនក្រ.តត

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយសុវត្ថារា**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាល ខេត្តកោះកុង

**សម្រេច**

**មាត្រា ១.**-បំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ចំនួន ៣៨គ្រឿង ជូនមន្ត្រីរាជការ ចំនួន ៣៨រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ និងបានចូលរួមកសាងអភិវឌ្ឍន៍ភូមិ-ឃុំនានាក្នុងខេត្តកោះកុង កន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ**

| | | |
|---|---|---|
| ១- | លោក ជូ សេរីយ៉ា | អនុប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្ត |
| ២- | លោក កែវ ទរ៉ាឌុល្ល | នាយករងទីចាត់ការរដ្ឋបាល |
| ៣- | លោក អ៊ុក សុគា | នាយករងទីចាត់ការអន្តរវិស័យ |
| ៤- | លោក ម៉ុច ពន្លក | នាយករងទីចាត់ការផែនការ និងវិនិយោគ |
| ៥- | លោកវរអគ្គានុរក្ស .១ វ័ន្ត ធី | អត្តលេខ 0110 អនុប្រធានពន្ធនាគារខេត្តបាត់ដំបង |
| ៦- | លោកវរអគ្គានុរក្ស .១ តាម ទៃ | អត្តលេខ 0111 អនុប្រធានពន្ធនាគារខេត្តបាត់ដំបង |
| ៧- | លោកវរអគ្គានុរក្ស .១ យ៉ន សុទឿត | អត្តលេខ 0296 ប្រធានការិយាល័យមធ្យោបាយ |
| ៨- | លោកសាស្ត្រាចារ្យ ស៊ីសុវត្ថិ បញ្ញាមុនី | គ្រូបច្ចេកទេសកម្រិតឧត្តម |
| ៩- | លោក អាយ សុគីរិទ្ធី | អនុប្រធានការិយាល័យសុរិយោដីក្រុងខេមរភូមិន្ទ |
| ១០- | លោក ឃុត ទ៉ាន់ដា | ប្រធានការិ.កិច្ចការច្បាប់ និងសុវត្ថភាពសាធារណៈ |
| ១១- | លោក អ៊ុក ចន្ថា | ប្រធានការិយាល័យបុគ្គលិក |
| ១២- | លោកវរសេនីយ៍ទោ ចុង ឆៃយ៉ា | អត្តលេខ 014172 អនុប្រធានក្រុមការងារទំនាក់ទំនងព្រំដែនកម្ពុជាថៃ ច្រកទ្វារចាំយាម |
| ១៣- | លោក វរសេនីយ៍ត្រី សុខ ផន | អត្តលេខ08218 អធិការស្រុកបូទុមសាគរ |
| ១៤- | លោកវរសេនីយ៍ត្រី អេលីត ជាទីត | អត្តលេខ 61733 នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិចាំយាម |

១៥- លោកវរសេនីយ៍ត្រី ឈុន រស្មី អត្តលេខ 038650 ជំនួយការខុទ្ទកាល័យអគ្គបញ្ជាការដ្ឋាន
១៦-លោកអនុសេនីយ៍ឯក ឆឹង ខាសនា អត្តលេខ 54508 នាយផ្នែករដ្ឋបាលសវនកម្មទី៤
១៧- លោកអនុសេនីយ៍ទោ ចំរើន បញ្ញា អត្តលេខ 65713 នាយផ្នែករដ្ឋបាលសរុប
១៨- លោកវរអគ្គានុរក្ស .៣ គ្រួន សារិទ្ធ អត្តលេខ 0640 ប្រធានផ្នែកបណ្តុះបណ្តាល និងផលិតកម្ម
១៩- លោកវរអគ្គានុរក្ស .៣ សំអុល តាំងប៊ូ អត្តលេខ 2112 មន្ត្រី
២០- លោកវរអគ្គានុរក្ស .៣ យិន សុខ អត្តលេខ 1119 មន្ត្រី
២១-លោកអនុរក្ស .១ សំអុល ស៊ីណេត អត្តលេខ 2107 មន្ត្រី
២២-លោកអនុរក្ស .២ ព្រំ សុខ អត្តលេខ 2113 មន្ត្រី

**ខ.មេដាយសុវត្ថារា ថ្នាក់ សេនា**

១- លោកវរអគ្គានុរក្ស .២ សេង សុខា អត្តលេខ 0297 ប្រធានការិយាល័យអប់រំកែប្រែ
២- លោកវរអគ្គានុរក្ស .២ ស៊ុយ អេង អត្តលេខ 0471 អនុប្រធានការិយាល័យប្រតិបត្តិ
៣- លោកវរអគ្គានុរក្ស .៣ ឌុល ប៊ុនធីរៈ អត្តលេខ 0479 អនុប្រធានការិយាល័យអប់រំកែប្រែ
៤- លោកវរអគ្គានុរក្ស .៣ សោម បូរិន្ទ អត្តលេខ 0702 ប្រធានផ្នែកអប់រំកែប្រែ
៥- លោកវរអគ្គានុរក្ស .២ ធឹម បូណា អត្តលេខ 0699 ប្រធានផ្នែកបណ្តុះបណ្តាល និងផលិតកម្ម
៦- លោកស្រីវរអគ្គានុរក្ស .៣ រីម សុផុល អត្តលេខ 0704 ប្រធានផ្នែករដ្ឋបាលសរុប
៧- លោកវរអគ្គានុរក្ស .២ ជឿន តាព អត្តលេខ 1257 អនុប្រធានផ្នែកអប់រំកែប្រែ
៨- លោកវរអគ្គានុរក្ស .៣ សុខ រ៉ុន អត្តលេខ 1258 អនុប្រធានផ្នែកអគ្គានុរក្ស

**គ.មេដាយសុវត្ថារា ថ្នាក់ អស្សឫទ្ធិ**

១- លោកវរអគ្គានុរក្ស .៣ ខួន កែវមុន្នី អត្តលេខ 1267 អនុប្រធានផ្នែករដ្ឋបាល
២- លោកវររគ្គានុរក្ស .៣ ចៅ សោម អត្តលេខ 1679 មន្ត្រី
៣- លោកវរអគ្គានុរក្ស .៣ ហាក់ លីនាង អត្តលេខ 2250 មន្ត្រី
៤- លោកអគ្គានុរក្ស .២ ឈឿត ចិន្តិកា អត្តលេខ 1264 អនុប្រធានផ្នែកអគ្គានុរក្ស
៥- លោកអគ្គានុរក្ស .២ ឡាច បូរ៉េន អត្តលេខ 1271 អនុប្រធានផ្នែកស៊ើបការអប់រំ
៦- លោកអគ្គានុរក្ស .២ ផល សុធា អត្តលេខ 1272 អនុប្រធានផ្នែកអគ្គានុរក្ស
៧- លោកវរអគ្គានុរក្ស .៣ ឃឹម ខេន អត្តលេខ 0647 ប្រធានផ្នែកសុខាភិបាល
៨- លោកអគ្គានុរក្ស .២ ម៉ន ពិសី អត្តលេខ 1116 អនុប្រធានផ្នែកអប់រំកែប្រែ

**មាត្រា ២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តកោះកុង និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ ឧសភា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៥៧៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អភិបាលនៃគណៈអភិបាល ខេត្តកោះកុង

## សម្រេច

**មាត្រា ១.** បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ចំនួន ៤៦គ្រឿង ជូនមន្ត្រីរាជការ ចំនួន ៤៦រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ និងបានចូលរួមកសាងអភិវឌ្ឍន៍ភូមិ-ឃុំនានា ក្នុងខេត្តកោះកុង កន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសការងារ**

| | | | | |
|---|---|---|---|---|
| ១- | លោក | អន | សុធារិទ្ធ | អភិបាលរងស្រុកបូទុមសាគរ |
| ២- | លោកសាស្ត្រាចារ្យ | ស៊ីសុវត្ថិ | ឫទ្ធីវ៉ាវង្ស | នាយករងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត |
| ៣- | លោកស្រី | ញ៉ឹក | សុវណ្ណារី | នាយិកាវិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ច |
| ៤- | លោក | គង់ | សុគណារ៉ា | នាយករងវិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ច |
| ៥- | លោក | អ៊ឹង | សំអឿន | ប្រធានការិយាល័យអភិវឌ្ឍន៍ និងសំណង់ |
| ៦- | លោក | ហេង | សុលី | ប្រធានការិយាល័យកិច្ចការសេដ្ឋកិច្ច និងសង្គមកិច្ច |
| ៧- | លោក | លី | ច័ន្ទរាសី | ប្រធានការិយាល័យផែនការ និងវិនិយោគ |
| ៨- | លោក | ធីវ | គានថាង | ប្រធានការិយាល័យទំនាក់ទំនង សាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ |
| ៩- | លោកស្រី | អ៊ិន | សោភ័ណ្ឌ | នាយករដ្ឋបាលស្រុកបូទុមសាគរ |
| ១០- | លោក | សាង | ស៊ីណេត | នាយករងរដ្ឋបាលស្រុកបូទុមសាគរ |
| ១១- | លោក | ម៉ូ | វាសនា | ប្រធានការិយាល័យរ៉ែ និងថាមពល |
| ១២- | លោក | ខន | សុវិធី | អនុប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ |
| ១៣- | លោក | នួវ | សុទ្ធារិទ្ធ | អនុប្រធានការិយាល័យ |
| ១៤- | លោក | សេង | ដុល | អនុប្រធានការិយាល័យប្រឡង |
| ១៥- | លោក | សាន់ | សម្បត្តិ | គ្រូបច្ចេកទេសកម្រិតឧត្តម |
| ១៦- | លោក | សួស | លាង | គ្រូបច្ចេកទេសកម្រិតឧត្តម |
| ១៧- | លោក | នាង | វុទ្ធី | គ្រូបច្ចេកទេសកម្រិតឧត្តម |

១៨- លោក ច្រឹង ណារី គ្រូបច្ចេកទេសកម្រិតឧត្តម
១៩- លោក រស់ បូរី មន្ត្រីពត៌មានវិទ្យាថ្នាក់ខេត្ត
២០- លោក គិន ប៊ុរាន អនុប្រធានការិ.ឧស្សាហកម្ម ទេសចរណ៍
២១- លោកស្រីវរអគ្គានុរក្ស .២ ទ័រ សុផល អត្តលេខ 0440 អនុប្រធានការិយាល័យរដ្ឋបាល
២២-លោកវរអគ្គានុរក្ស .៣ ព្រុំ សារី អត្តលេខ 1112 អនុប្រធានផ្នែកគណនេយ្យ
២៣ -លោកវរអគ្គានុរក្ស .៣ ទ្រី សុវណ្ណមហាសម្រិការ អត្តលេខ 2108 មន្ត្រី
២៤-លោកអនុសេនីយ៍ទោ សេង រ័ត្ននរិទ្ធ មន្ត្រីអង្គភាពអន្តរាគមន៍ពិសេស
២៥- លោកអនុសេនីយ៍ឯក សួស វ៉ាសាក់ អត្តលេខ 010677 អនុប្រធានផ្នែកល្បាតត្រួតពិនិត្យ
២៦- លោកអនុសេនីយ៍ឯក ឆុល នំភូធូរ៉ា អត្តលេខ 59866 នាយផ្នែកច្បាមការពារ
២៧-លោកអនុសេនីយ៍ឯក ឆេព សុភ័ក្រ្ត អត្តលេខ 61875 នាយរងផ្នែកបែបបទ
២៨-លោកអនុសេនីយ៍ទោ គឹម ចាន់ដារ៉ា អត្តលេខ 20895 នាយរងផ្នែកបច្ចេកទេសស្រុកកៀនស្វាយ
២៩- លោកអនុសេនីយ៍ត្រី ម៉ួយ ណារិទ្ធ អត្តលេខ 56410 អនុប្រធានក្រុមទិដ្ឋាការ
៣០-លោកអនុសេនីយ៍ត្រី ជា ខួនសក្តិ អត្តលេខ 74747 មន្ត្រីកងអន្តរាគមខេត្តកណ្តាល
៣១-លោកព្រិន្ទបាលឯក ភុល សុផាត អត្តលេខ 40734 នគរបាលប៉ុស្តិ៍សំរោងធំ
៣២-លោកព្រិន្ទបាលឯក ឆឹង រិទ្ធី អត្តលេខ 58494 មន្ត្រីអធិការនគរបាល ក្រុងតាខ្មៅ
៣៣-លោកព្រិន្ទបាលឯក ផល វណ្ណា អត្តលេខ 58251 មន្ត្រីប៉ុស្តិ៍នគរបាល ក្រុងតាខ្មៅ
៣៤-លោក ឡាំ ធី ស្មៀនឃុំប៉ាក់ខ្លង
៣៥-លោក ធី វិច ស្មៀនឃុំពាមក្រសោប

**ខ-មេដាយប្រាក់ការងារ**

១-លោក ជា ពន្ធ្យ គ្រូបច្ចេកទេសកម្រិតឧត្តម
២-លោក ជុន សេងហាក់ គ្រូបច្ចេកទេសកម្រិតឧត្តម
៣-លោកស្រី ពេជ្រ សំអាត គ្រូបច្ចេកទេសជាប់កិច្ចសន្យា
៤-លោក សាង វន្នី អនុប្រធានការិយាល័យអភិវឌ្ឍន៍ និងសំណង់
៥-លោក ទន់ ស៊ីគូ អនុប្រធានការិយាល័យសរុប និងពត៌មាន
៦-លោក ខេង គង់ ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុស្រុក
៧-លោក សយ សុវណ្ណ ស្មៀនឃុំតាទួន
៨-កញ្ញាអនុរក្ស .៣ អៀង ពុធនីកា អត្តលេខ 2425 មន្ត្រី
៩-លោកអនុរក្ស .៣ ឈាង ពិសិដ្ឋ អត្តលេខ 2428 មន្ត្រី
១០-លោកអគ្គានុរក្ស .២ អៀង ស៊ីណា អត្តលេខ 1109 អនុប្រធានផ្នែកអគ្គានុរក្ស
១១-លោក ឆេង សុខឿយ មន្ត្រីសាលាខេត្ត

**មាត្រា ២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តកោះកុង និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែ ឧសភា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៥៣០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពារតំបន់រមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា " **អាជ្ញាធរអប្សរា** "
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា "**អាជ្ញាធរអប្សរា**"
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៦៧ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលមាត្រា ៤ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា " **អាជ្ញាធរអប្សរា** "
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៦១៣ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការកែសម្រួលមាត្រា ៤ ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៦៧ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលមាត្រា ៤ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា " **អាជ្ញាធរអប្សរា** "

- បានឃើញអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**សម្រេច**

**មាត្រា ១.-**

តែងតាំងមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានអាជ្ញាធរអប្សរា ចំនួន ០៣ រូប ៖

១. លោក **ជ្រុន សុផល** ជាឧបការី នៃអាជ្ញាធរអប្សរា មានឋានៈស្មើ **អគ្គនាយករង**

២. លោក **គង់ មរកត** ជាឧបការី នៃអាជ្ញាធរអប្សរា មានឋានៈស្មើ **អគ្គនាយករង**

៣. លោក **ឡុង កុសល** ជាប្រធាននាយកដ្ឋានផ្សព្វផ្សាយ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៣១ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការដូនមេដាយការងារ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

## សម្រេច

**មាត្រា១.** បំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការចំនួន ០៩រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១- | លោក **ឆេង សុគន្ធ** | អនុប្រធាននាយកដ្ឋាន |
| ២- | លោកស្រី **ស្វាយ សុធី** | អនុប្រធាននាយកដ្ឋាន |
| ៣- | លោកស្រី **សូ សុខា** | អនុប្រធាននាយកដ្ឋាន |
| ៤- | លោក **កែវ សម្បត្តិ** | អនុប្រធាននាយកដ្ឋាន |
| ៥- | លោក **សួស ម៉ុនថន** | អនុប្រធាននាយកដ្ឋាន |
| ៦- | លោក **ថៃ ពិសិដ្ឋ** | អនុប្រធាននាយកដ្ឋាន |
| ៧- | លោក **សាខុន ប៊ូរី** | អនុប្រធាននាយកដ្ឋាន |
| ៨- | លោក **ធួន សុខជា** | អនុប្រធាននាយកដ្ឋាន |
| ៩- | លោក **លឹម ហេង** | អនុប្រធាននាយកដ្ឋាន |

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៧៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិថ្នាក់**វរសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ចំនួន ០៣រូប នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម៖

១-លោកវរសេនីយ៍ទោ **ណុប សារឹម** អត្តលេខ ៣០៧០៥
២-លោកវរសេនីយ៍ទោ **ពេជ្រ មុន្នីរ័តន៍** អត្តលេខ ៥៥៤១៦
៣-លោកវរសេនីយ៍ទោ **ម៉ម ដារ៉េត** អត្តលេខ ៥៥៤៤៤។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១៥
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
-ដូចមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៣៣ អនក្រ.បក

# អនុក្រឹត្យ

**ស្ដីពី**

**ការដំឡើងឋានន្តរស័ក្តិ នាយទាហាន**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្ដីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិ ថ្នាក់ វរនាវីឯក នាយទាហាននៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោមៈ

១-វរនាវីទោ **ឡឹក សាថន** អត្តលេខ ០៩១២២០ នាយសេនាធិការរង មូលដ្ឋានសមុទ្រ បញ្ជាការដ្ឋានកងទ័ពជើងទឹក

២-វរនាវីទោ **ពៅ សុខឿន** អត្តលេខ ០១៥០៩០ មេបញ្ជាការ កងការពារកោះពូលូវៃ៥ កងពលតូចការពារកោះឆ្មេរលេខ៣១

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៣៤ - អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តកណ្តាល

## សម្រេច

**មាត្រា ១.-** បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ២៥គ្រឿង ប្រគេន និង ជូនសប្បុរសជន ដែលបានបរិច្ចាគបច្ច័យផ្ទាល់ខ្លួន ចូលរួមកសាងសមិទ្ធផលនានា លើវិស័យព្រះពុទ្ធសាសនា និងសង្គម នៅវត្តព្រែកបង្កង កន្ទុងមក ដូចមានរាយព្រះនាម និងនាមខាងក្រោម៖

**ក-មេដាយមាសស្ថាបនាជាតិ**

១- ព្រះតេជគុណ **ប៊ុត មានុប**
២- ព្រះតេជគុណ **ហុក សុវណ្ណារ៉ូ**
៣- ព្រះតេជគុណ **ប៊ិច ចំរើន**
៤- ព្រះតេជគុណ **ព្រាលីខ គត្តី**
៥- កញ្ញា **ផៃ ម៉្លិះ**
៦- លោក **ស្រ៊ុន ចាយ**
៧- ឧបាសក **ផុន ផាត**
៨- ឧបាសក **ហ៊ឹម ប៉ាក់**
៩- ឧបាសក **ជា មើម**

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

១- ឧបាសក **គួច សុន**
២- ឧបាសិកា **ជីវ គីមហួយ**
៣- ឧបាសិកា **ជា ឧត**
៤- ឧបាសិកា **មុំ មិត**

៥- ឧបាសិកា ឈួន ស្រៀង
៦- ឧបាសក ខៀវ ឆយ
៧- ឧបាសក ម៉ាន់ សារឿន
៨- ឧបាសក យន់ សម្បត្តិ
៩- ឧបាសិកា អែល រុន
១០- ឧបាសក នៅ ហ៊ាន
១១- ឧបាសក ម៉ឺង មើ
១២- ឧបាសក ឃិប ស៊ុំ
១៣- ឧបាសិកា ខោល ម៉ាស
១៤- លោក គង់ គីមសាន្ត
១៥- លោក ផ្លុង ឆុប
១៦- លោក សុខ ឆុច

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលខេត្តកណ្តាល និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២០ ខែ ឧសភា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៣៦ អនក្រ.បក

# អនុក្រឹត្យ

**ស្តីពី**

**ការផ្ទេរ បញ្ចូលក្របខ័ណ្ឌ និងប្រគល់ឋានន្តរស័ក្តិ**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣, ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**មាត្រា១ :** ផ្ទេរ បញ្ចូលក្របខ័ណ្ឌ និងប្រគល់ឋានន្តរស័ក្តិ ថ្នាក់ វរសេនីយ៍ឯក ជូន លោក **រ៉ុង រតនៈ** អត្តលេខ ០១១២៤១ ជំនួយការ ខុទ្ទកាល័យ ក្រសួងការពារជាតិ ។

